ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ១១៧ ព.ណ.ឥបព.ប្រក

# ប្រកាស

## ស្តីពី

## ការធ្វើសាមញ្ញកម្មនៃការងារចុះបញ្ជីពាណិជ្ជកម្ម

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២២/០០២ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២២/០០៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ២៣៨ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ._**

ប្រកាសនេះមានគោលបំណងប្រមូលផ្តុំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់នានាទាក់ទងនឹងការងារចុះបញ្ជី ដើម្បីសម្រួលជានាបាននូវប្រសិទ្ធភាព ភាពងាយស្រួល និងល្អប្រសើរនៃនីតិវិធីចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២ ._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះពាណិជ្ជករ និងក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយ ដែលមានគ្រឹះស្ថាន សាខា ការិយាល័យតំណាង បុត្រសម្ព័ន្ធ ឬទីភ្នាក់ងាររបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ការស្នើសុំដាក់ពាក្យសម្គាល់ទ្រង់ទ្រាយក្រុមហ៊ុន

**ប្រការ៣ ._**

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតដែលអនុញ្ញាតឱ្យប្រើពាក្យ ហូលឌីង (HOLDING) ឬគ្រុប (GROUP) នៅបន្ទាប់ពីឈ្មោះក្រុមហ៊ុន ត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖

១. នាមករណ៍ក្រុមហ៊ុនដែលប្រើពាក្យ ហូលឌីង (HOLDING)
   - ក. ត្រូវមានក្រុមហ៊ុនជាបុត្រសម្ព័ន្ធយ៉ាងតិច ៣(បី)ក្រុមហ៊ុន ដែលបានចុះបញ្ជីក្នុងព្រះរាជាណាចក្រកម្ពុជា
   - ខ. ក្រុមហ៊ុនដើម ជាក្រុមហ៊ុនដែលត្រូវមានកម្មវត្ថុអាជីវកម្មលេខ ៦៤២ (សកម្មភាពរបស់ក្រុមហ៊ុនភាគហ៊ុន) និងផ្តល់ទុនទៅឱ្យក្រុមហ៊ុនជាបុត្រសម្ព័ន្ធដើម្បីធ្វើពាណិជ្ជកម្ម។ ក្រុមហ៊ុនដើម មិនអាចធ្វើសកម្មភាពពាណិជ្ជកម្មដោយផ្ទាល់បានឡើយ
   - គ. ក្រុមហ៊ុនដើម ត្រូវកាន់កាប់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតយ៉ាងតិច ៥១% (ហាសិបមួយភាគរយ) នៅក្នុងក្រុមហ៊ុនជាបុត្រសម្ព័ន្ធនីមួយៗ

២. នាមករណ៍ក្រុមហ៊ុនដែលប្រើពាក្យ គ្រុប (GROUP)
   - ក. ត្រូវមានក្រុមហ៊ុនជាបុត្រសម្ព័ន្ធយ៉ាងតិច ៣(បី)ក្រុមហ៊ុន ដែលបានចុះបញ្ជីក្នុងព្រះរាជាណាចក្រកម្ពុជា
   - ខ. ក្រុមហ៊ុនដើម ត្រូវកាន់កាប់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតយ៉ាងតិច ៥១% (ហាសិបមួយភាគរយ) នៅក្នុងក្រុមហ៊ុនជាបុត្រសម្ព័ន្ធនីមួយៗ។

ការទទួលស្គាល់នាមករណ៍ក្រុមហ៊ុនដែលប្រើពាក្យ ហូលឌីង (HOLDING) ឬគ្រុប (GROUP) ឬនាមករណ៍ដែលមានលក្ខណៈស្រដៀងគ្នា ត្រូវសម្រេចដោយលិខិតអនុញ្ញាតរបស់ក្រសួងពាណិជ្ជកម្ម។

## ជំពូកទី៣
## ការចុះបញ្ជីបង្កើតក្រុមហ៊ុនពាណិជ្ជកម្ម

**ប្រការ៤ ._**

រាល់ពាណិជ្ជករ និងក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយ ដែលមានគ្រឹះស្ថាន សាខា ការិយាល័យតំណាង បុត្រសម្ព័ន្ធ ឬទីភ្នាក់ងាររបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ចចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មានតាមរយៈគេហទំព័រ www.registrationservices.gov.kh ពីគ្រប់ទីកន្លែង។

តារាងបង្ហាញលំហូរនៃនីតិវិធីចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ដូចមានជូនភ្ជាប់ក្នុង**ឧបសម្ព័ន្ធទី១** នៃប្រកាសនេះ។

**ប្រការ៥ ._**

ពាណិជ្ជករ ម្ចាស់ហ៊ុន ឬអភិបាល ត្រូវបំពេញនូវរាល់ព័ត៌មាន ឯកសារ និងលក្ខខណ្ឌតម្រូវទាំងអស់តាមទម្រង់កំណត់នៅក្នុងថ្នាលបច្ចេកវិទ្យាព័ត៌មាន។



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីមែល៖ cabinet.info@moc.gov.kh

ព័ត៌មាន និងឯកសារសម្រាប់ការស្នើសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ដែលបានបំពេញដោយពាណិជ្ជករ ម្ចាស់ហ៊ុន ឬអភិបាល និងឯកសារតម្រូវសម្រាប់តម្កល់នៅក្រសួងពាណិជ្ជកម្ម ត្រូវបញ្ចូលតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ជាទម្រង់អេឡិចត្រូនិក។

ក្នុងករណី ពាណិជ្ជករ ម្ចាស់ហ៊ុន ឬអភិបាល មិនអាចបំពេញនូវព័ត៌មាន និងបញ្ចូលលក្ខខណ្ឌតម្រូវក្នុងថ្នាលបច្ចេកវិទ្យាព័ត៌មានដោយខ្លួនឯងបាន ពាណិជ្ជករ ម្ចាស់ហ៊ុន ឬអភិបាលអាចមកក្រសួងពាណិជ្ជកម្ម ដើម្បីស្នើសុំឱ្យមន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ឬភ្នាក់ងារចុះបញ្ជីបំពេញនូវរាល់ព័ត៌មាន ឯកសារ និងលក្ខខណ្ឌតម្រូវក្នុងថ្នាលបច្ចេកវិទ្យាព័ត៌មានជំនួស។

**ប្រការ៦ .-**

ព័ត៌មាន និងឯកសារតម្រូវសម្រាប់ការស្នើសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ដែលត្រូវបញ្ចូលតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ជាទម្រង់អេឡិចត្រូនិក មានដូចខាងក្រោម៖

**ក. ការចុះបញ្ជីក្រុមហ៊ុន**

១. ឯកសារបញ្ជាក់អាសយដ្ឋានទីស្នាក់ការចុះបញ្ជី ណាមួយដូចខាងក្រោម៖
- បណ្ណកម្មសិទ្ធិ
- កិច្ចសន្យាជួលទីតាំង
- កិច្ចសន្យាលក់ទិញធ្វើឡើងជាទម្រង់លិខិតយថាភូត
- វិក្កយបត្រទឹក ឬវិក្កយបត្រអគ្គិសនី
- លិខិតអនុញ្ញាតឱ្យប្រើប្រាស់ទីតាំង ឬ
- លិខិតបញ្ជាក់ពីអាជ្ញាធរដែនដី

២. លក្ខន្តិកៈក្រុមហ៊ុន

៣. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ម្ចាស់ហ៊ុន អភិបាល ឬអ្នកតំណាងនីតិបុគ្គល

៤. រូបថត ៤X៦ ផ្ទៃខាងក្រោយពណ៌ស មិនលើសពីរយៈពេល ៣ (បី) ខែ

៥. ករណីម្ចាស់ហ៊ុនជានីតិបុគ្គល៖
- ច្បាប់ចម្លងឯកសារគតិយុត្តនៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើម បញ្ជាក់ដោយសារការីនៃព្រះរាជាណាចក្រកម្ពុជា ឬស្ថានទូត ឬស្ថានកុងស៊ុល ឬសភាពាណិជ្ជកម្មបរទេស ដែលទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម
- លិខិតប្រគល់សិទ្ធិ ឬសេចក្តីសម្រេចម្ចាស់ហ៊ុនក្នុងការបង្កើតក្រុមហ៊ុន និងតែងតាំងអ្នកតំណាងនីតិបុគ្គលជាម្ចាស់ហ៊ុន

៦. ការពិនិត្យសាវតារូបវន្តបុគ្គលសំដៅជានាការប្រឆាំងលាងសម្អាតប្រាក់តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

**ខ. ការចុះបញ្ជីក្រុមហ៊ុនពាណិជ្ជកម្មបរទេស**

១. ឯកសារបញ្ជាក់អាសយដ្ឋានទីស្នាក់ការចុះបញ្ជី ណាមួយដូចខាងក្រោម៖
- បណ្ណកម្មសិទ្ធិ
- កិច្ចសន្យាជួលទីតាំង
- កិច្ចសន្យាលក់ទិញធ្វើឡើងជាទម្រង់លិខិតយថាភូត
- វិក្កយបត្រទឹក ឬវិក្កយបត្រអគ្គិសនី
- លិខិតអនុញ្ញាតឱ្យប្រើប្រាស់ទីតាំង ឬ
- លិខិតបញ្ជាក់ពីអាជ្ញាធរដែនដី

២. ច្បាប់ចម្លងឯកសារគតិយុត្តនៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើម បញ្ជាក់ដោយសារការីនៃព្រះរាជាណាចក្រកម្ពុជា ឬស្ថានទូត ឬស្ថានកុងស៊ុល ឬសភាពាណិជ្ជកម្មបរទេស ដែលទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម ក្នុងនោះរួមមាន៖
- ច្បាប់ចម្លងវិញ្ញាបនបត្រក្រុមហ៊ុនដើម
- ច្បាប់ចម្លងលក្ខន្តិកៈក្រុមហ៊ុនដើម



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីមែល៖ cabinet.info@moc.gov.kh

៣. លិខិតប្រគល់សិទ្ធិ ឬសេចក្តីសម្រេចម្ចាស់ហ៊ុនក្នុងការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មបរទេស និងតែងតាំងអ្នកតំណាងស្របច្បាប់
៤. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកតំណាងស្របច្បាប់
៥. រូបថត ៤X៦ ផ្ទៃខាងក្រោយពណ៌ស មិនលើសពីរយៈពេល ៣ (បី) ខែ
៦. ការពិនិត្យសាវតាររូបវន្តបុគ្គលសំដៅធានាការប្រឆាំងលាងសម្អាតប្រាក់តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

**គ. ការចុះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិ**

១. ឯកសារបញ្ជាក់អាសយដ្ឋានទីស្នាក់ការចុះបញ្ជី ណាមួយដូចខាងក្រោម៖
- បណ្ណកម្មសិទ្ធិ
- កិច្ចសន្យាជួលទីតាំង
- កិច្ចសន្យាលក់ទិញធ្វើឡើងជាទម្រង់លិខិតយថាភូត
- វិក្កយបត្រទឹក ឬវិក្កយបត្រអគ្គិសនី
- លិខិតអនុញ្ញាតឱ្យប្រើប្រាស់ទីតាំង ឬ
- លិខិតបញ្ជាក់ពីអាជ្ញាធរដែនដី

២. កិច្ចសន្យាបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ
៣. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់សហកម្មសិទ្ធិករ និងអ្នកគ្រប់គ្រង
៤. រូបថត ៤X៦ ផ្ទៃខាងក្រោយពណ៌ស មិនលើសពីរយៈពេល ៣ (បី) ខែ
៥. ករណីសហកម្មសិទ្ធិករជានីតិបុគ្គល៖
- ច្បាប់ចម្លងឯកសារគតិយុត្តនៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើម បញ្ជាក់ដោយសារការីនៃព្រះរាជាណាចក្រកម្ពុជា ឬស្ថានទូត ឬស្ថានកុងស៊ុល ឬសភាពាណិជ្ជកម្មបរទេស ដែលទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម
- លិខិតប្រគល់សិទ្ធិ ឬសេចក្តីសម្រេចក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ និងតែងតាំងអ្នកតំណាងនីតិបុគ្គលជាសហកម្មសិទ្ធិករ

៦. ការពិនិត្យសាវតាររូបវន្តបុគ្គលសំដៅធានាការប្រឆាំងលាងសម្អាតប្រាក់តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

**ឃ. ការចុះបញ្ជីសហគ្រាសឯកបុគ្គល**

១. ឯកសារបញ្ជាក់អាសយដ្ឋានទីស្នាក់ការចុះបញ្ជី ណាមួយដូចខាងក្រោម៖
- បណ្ណកម្មសិទ្ធិ
- កិច្ចសន្យាជួលទីតាំង
- កិច្ចសន្យាលក់ទិញធ្វើឡើងជាទម្រង់លិខិតយថាភូត
- វិក្កយបត្រទឹក ឬវិក្កយបត្រអគ្គិសនី
- លិខិតអនុញ្ញាតឱ្យប្រើប្រាស់ទីតាំង
- លិខិតបញ្ជាក់ពីអាជ្ញាធរដែនដី

២. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ឯកកម្មសិទ្ធិករ
៣. រូបថត ៤X៦ ផ្ទៃខាងក្រោយពណ៌ស មិនលើសពីរយៈពេល ៣ខែ
៤. ការពិនិត្យសាវតាររូបវន្តបុគ្គលសំដៅធានាការប្រឆាំងលាងសម្អាតប្រាក់តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

**ប្រការ៧ .-**

ពាណិជ្ជករ ម្ចាស់ហ៊ុន ឬអភិបាលត្រូវធានាអះអាងចំពោះរាល់ព័ត៌មានសម្រាប់ការស្នើសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងឯកសារតម្រូវដែលខ្លួនបានបំពេញ និងបញ្ចូលតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ជាទម្រង់អេឡិចត្រូនិក រួមបញ្ចូលទាំងហត្ថលេខាឌីជីថល ដែលអនុលោមស្របតាមបទប្បញ្ញត្តិជាធរមាន (ប្រសិនបើមាន) ថាពិតជាព័ត៌មាន ឯកសារត្រឹមត្រូវ និងមិនក្លែងបន្លំ។



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីមែល៖ cabinet.info@moc.gov.kh

ប្រសិនបើមន្ត្រីចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្មរកឃើញថា ព័ត៌មាននិងឯកសារមិនត្រឹមត្រូវ ឬមានការក្លែងបន្លំ ក្រសួងពាណិជ្ជកម្មនឹងចាត់វិធានការតាមមាត្រា២៦ថ្មី(ពីរ) នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ហើយពាណិជ្ជករ សហកម្មសិទ្ធិករ ស្ថាបនិក ម្ចាស់ហ៊ុន ឬអភិបាលនោះ ត្រូវទទួលទោសដូចមានកំណត់ក្នុងមាត្រា៤៣ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ព្រមទាំងច្បាប់ពាក់ព័ន្ធដទៃទៀតជាធរមាន។

ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ក្រុមហ៊ុនត្រូវផ្ញើមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនូវឯកសារដូចរៀបរាប់ខាងលើចំនួន ២ (ពីរ) ច្បាប់។

ក្រុមហ៊ុនអាចស្នើសុំលក្ខន្តិកៈដែលតម្កល់រួចទៅប្រើប្រាស់ដោយមិនចាំបាច់ផ្ញើយថាភូតភាព តាមរយៈ verify.gov.kh។

សហកម្មសិទ្ធិករ អាចយកកិច្ចសន្យាបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ ដែលតម្កល់រួចទៅប្រើប្រាស់តាមរយៈ verify.gov.kh ដោយមិនចាំបាច់ផ្ញើយថាភូតភាព។

ក្នុងករណីនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម មិនបានទទួលលក្ខន្តិកៈច្បាប់ដើម ឬកិច្ចសន្យាបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ ក្នុងចិរវេលា ៣០ (សាមសិប)ថ្ងៃ នោះទេ ក្រសួងពាណិជ្ជកម្មអាចលុបចោលការចុះបញ្ជីពាណិជ្ជកម្ម។

## ជំពូកទី៤
## ការចុះបញ្ជីបង្កើតសាខាក្រុមហ៊ុនក្នុងស្រុក

**ប្រការ៨ .-**

រាល់ពាណិជ្ជករ និងក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយ ដែលបានចុះបញ្ជីបង្កើតឡើងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា អាចបង្កើតសាខាក្រុមហ៊ុនក្នុងស្រុកមួយ ឬច្រើនបាន។

ក្រុមហ៊ុនដែលបង្កើតសាខា ត្រូវហៅថា "ក្រុមហ៊ុនដើម"។ ក្រុមហ៊ុនដើមត្រូវទទួលខុសត្រូវលើសកម្មភាព និងកាតព្វកិច្ចរបស់សាខាក្រុមហ៊ុនក្នុងស្រុក។

តារាងបង្ហាញលំហូរនៃនីតិវិធីចុះបញ្ជីបង្កើតសាខាក្រុមហ៊ុនក្នុងស្រុកដូចមានជូនភ្ជាប់ក្នុង**ឧបសម្ព័ន្ធទី២** នៃប្រកាសនេះ។

**ប្រការ៩ .-**

ម្ចាស់ហ៊ុន ឬអភិបាល ដែលមានបំណងចង់បង្កើតសាខាក្រុមហ៊ុនក្នុងស្រុករបស់ខ្លួនអាចស្នើសុំមកក្រសួងពាណិជ្ជកម្ម តាមរយៈការិយាល័យចុះបញ្ជីពាណិជ្ជកម្ម នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ដើម្បីដាក់ពាក្យស្នើសុំ និងភ្ជាប់មកជាមួយនូវឯកសារតម្រូវដូចមានកំណត់ក្នុងប្រការ១០ នៃប្រកាសនេះ ជូនក្រសួងពាណិជ្ជកម្ម ដើម្បីទទួលចុះបញ្ជីសាខាក្រុមហ៊ុនក្នុងស្រុក។

**ប្រការ១០ .-**

សំណុំឯកសារចុះបញ្ជីបង្កើតសាខាក្រុមហ៊ុនក្នុងស្រុក ដែលត្រូវប្រគល់តាមច្រកចេញចូលតែមួយនៃក្រសួងពាណិជ្ជកម្ម មានដូចខាងក្រោម៖

១. សំណើស្នើសុំ (១ ច្បាប់)
២. លិខិតប្រគល់សិទ្ធិ (១ ច្បាប់)
៣. ឯកសារបញ្ជាក់អាសយដ្ឋានទីស្នាក់ការចុះបញ្ជីសាខា (១ ច្បាប់)
៤. នាយកគ្រប់គ្រង (១ ច្បាប់)
 - អត្តសញ្ញាណប័ណ្ណ (សញ្ជាតិខ្មែរ) ឬលិខិតឆ្លងដែន (សញ្ជាតិបរទេស)
 - រូបថត ៤x៦ ផ្ទៃខាងក្រោយពណ៌ស មិនលើសពីរយៈពេល ៣ (បី) ខែ
៥. ឯកសារយោងពីក្រសួង-ស្ថាប័នពាក់ព័ន្ធ (១ ច្បាប់ ប្រសិនបើមាន)។

អភិបាល ១ (មួយ) រូប មានសិទ្ធិចុះហត្ថលេខាលើសំណើស្នើសុំ និងលិខិតប្រគល់សិទ្ធិ សម្រាប់ចុះបញ្ជីបង្កើតសាខាក្រុមហ៊ុនក្នុងស្រុកបាន។

ម្ចាស់ហ៊ុន ឬអភិបាលត្រូវធានាអះអាងចំពោះរាល់ព័ត៌មាន សម្រាប់ការស្នើសុំចុះបញ្ជីបង្កើតសាខាក្រុមហ៊ុនក្នុងស្រុក និងឯកសារតម្រូវដែលខ្លួនបានបំពេញ រួមបញ្ចូលទាំងហត្ថលេខាឌីជីថល ដែលអនុលោមស្របតាមបទប្បញ្ញត្តិជាធរមាន (ប្រសិនបើមាន) ថាពិតជាព័ត៌មាន ឯកសារត្រឹមត្រូវ និងមិនក្លែងបន្លំ។

## ជំពូកទី៥
## ការចុះបញ្ជីកែប្រែ

**ប្រការ១១ ._**

រាល់ពាណិជ្ជករ និងក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយ ដែលបានចុះបញ្ជីពាណិជ្ជកម្មមានកាតព្វកិច្ចចុះបញ្ជីនូវរាល់ការផ្លាស់ប្តូរ ឬកែប្រែរបស់សហគ្រាស ឬក្រុមហ៊ុន តាមប្រព័ន្ធស្វ័យប្រវត្តកម្មដែលកំណត់ដោយក្រសួងពាណិជ្ជកម្ម។

តារាងបង្ហាញលំហូរនៃនីតិវិធីចុះបញ្ជីកែប្រែ ដូចមានជូនភ្ជាប់ក្នុង**ឧបសម្ព័ន្ធទី៣** នៃប្រកាសនេះ។

**ប្រការ១២ ._**

សហគ្រាស ឬក្រុមហ៊ុន ត្រូវចុះបញ្ជីតាមការកំណត់ក្នុងប្រកាសនេះ ប្រសិនបើសហគ្រាស ឬក្រុមហ៊ុនមានការផ្លាស់ប្តូរ ឬកែប្រែណាមួយ ឬច្រើន ដូចខាងក្រោម៖

- ការផ្លាស់ប្តូរនាមករណ៍
- ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជី ឬព័ត៌មានទំនាក់ទំនង
- ការបន្ថែម ការបន្ថយ ឬការផ្លាស់ប្តូរកម្មវត្ថុអាជីវកម្ម
- ការបែងចែកសាជាថ្មីនូវចំនួនភាគហ៊ុនជាប្រភេទឡើងវិញ ដោយមានការកែប្រែលក្ខណៈដាច់ខាត និងលក្ខណៈធៀបរបស់ប្រភេទភាគហ៊ុនណាមួយ
- ការកែប្រែភាគលាភ នៃប្រភេទភាគហ៊ុនណាមួយ
- ការបង្កើនដើមទុនដោយបង្កើតភាគហ៊ុនថ្មី
- ការផ្ទេរ ឬទិញ-លក់ភាគហ៊ុន
- ការបន្ថយដើមទុនដោយបញ្ចុះតម្លៃចារឹកលើប័ណ្ណនៃប្រភេទភាគហ៊ុនណាមួយ
- ការកែប្រែចិរវេលានៃអត្តិភាព
- ការកែប្រែចំនួនអភិបាល
- ការផ្លាស់ប្តូរអភិបាល
- ការកែប្រែព័ត៌មានលម្អិតអភិបាល ម្ចាស់ហ៊ុន ឬអ្នកតំណាង
- ការផ្លាស់ប្តូរអ្នកតំណាងម្ចាស់ហ៊ុនជានីតិបុគ្គល
- ការផ្លាស់ប្តូរទ្រង់ទ្រាយ
- ការកែប្រែចំនួនកូរ៉ុម
- ការបន្ថយ ឬបន្ថែមបទប្បញ្ញត្តិណាមួយ ដែលច្បាប់អនុញ្ញាតឱ្យដាក់បញ្ចូលទៅក្នុងលក្ខន្តិកៈក្រុមហ៊ុន
- ការកែប្រែកិច្ចសន្យាបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ
- ការកែប្រែព័ត៌មានសហកម្មសិទ្ធិករ
- ការផ្លាស់ប្តូរព័ត៌មានលម្អិតរបស់ម្ចាស់សហគ្រាស
- ការផ្ទេរសិទ្ធិគ្រប់គ្រងសហគ្រាស
- ការកែប្រែសាខាក្រុមហ៊ុនក្នុងស្រុក
- ការលុបឈ្មោះសាខាក្រុមហ៊ុនក្នុងស្រុកចេញពីបញ្ជីពាណិជ្ជកម្ម។

**ប្រការ១៣ ._**

សំណុំឯកសារដែលត្រូវបញ្ចូលក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មជាទម្រង់អេឡិចត្រូនិក មានដូចខាងក្រោម៖

**ក. សំណុំឯកសារដែលត្រូវបញ្ចូលក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មជាទម្រង់អេឡិចត្រូនិកសម្រាប់សហគ្រាស និងក្រុមហ៊ុន៖**

- កំណត់ហេតុអង្គប្រជុំ ឬសេចក្តីសម្រេចរបស់ម្ចាស់ហ៊ុន
- លិខិតស្នើសុំធ្វើការផ្លាស់ប្តូរកែប្រែ
- ច្បាប់ចម្លងលិខិតគោលការណ៍ចេញពីស្ថាប័នពាក់ព័ន្ធ



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh

- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន និងរូបថតទំហំ ៤x៦ ផ្ទៃខាងក្រោយពណ៌សរបស់ម្ចាស់ហ៊ុនថ្មី អភិបាលថ្មី ឬអ្នកតំណាងថ្មីម្នាក់ៗ
- ក្នុងករណីម្ចាស់ហ៊ុនជានីតិបុគ្គល សាមីក្រុមហ៊ុនត្រូវភ្ជាប់ឯកសារដូចខាងក្រោម៖
  - ច្បាប់ចម្លងឯកសារគតិយុត្ត នៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើម (លក្ខន្តិកៈ និងវិញ្ញាបនបត្ររបស់ក្រុមហ៊ុន) និងសេចក្តីសម្រេចក្នុងការទិញភាគហ៊ុន និងការតែងតាំងអ្នកតំណាង (សម្រាប់ម្ចាស់ហ៊ុនថ្មីជានីតិបុគ្គល) បញ្ជាក់ដោយសារការីនៃព្រះរាជាណាចក្រកម្ពុជា ឬស្ថានទូត ឬស្ថានកុងស៊ុល ឬសភាពាណិជ្ជកម្មបរទេសដែលទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម
  - សេចក្តីសម្រេចក្នុងការផ្ទេរ ឬការលក់ភាគហ៊ុន ដោយមានការបញ្ជាក់ដោយសារការីនៃព្រះរាជាណាចក្រកម្ពុជា ឬស្ថានទូត ឬស្ថានកុងស៊ុល ឬសភាពាណិជ្ជកម្មបរទេសដែលទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម ឬតាមរយៈការស្នើសុំបំពេញនីតិវិធីផ្ទេរ ឬលក់ភាគហ៊ុនតាមប្រព័ន្ធអនឡាញ នៅចំពោះមុខមន្ត្រីចុះបញ្ជីនៃក្រសួងពាណិជ្ជកម្ម (សម្រាប់ការផ្ទេរ ឬលក់ភាគហ៊ុនម្ចាស់ហ៊ុនជានីតិបុគ្គល)

  * កំណត់ហេតុអង្គប្រជុំ ឬសេចក្តីសម្រេចរបស់ម្ចាស់ហ៊ុនលើការផ្ទេរភាគហ៊ុន ត្រូវធ្វើឡើងដោយស្របតាមបញ្ញត្តិនៃលក្ខន្តិកៈក្រុមហ៊ុននីមួយៗ
- ការពិនិត្យសាវតារបុគ្គលសម្រាប់ម្ចាស់ហ៊ុន ឬអភិបាលថ្មី សំដៅជានាការប្រឆាំងការសម្អាតប្រាក់តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

**ខ. សំណុំឯកសារដែលត្រូវតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម៖**

ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចុះបញ្ជីកែប្រែតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ក្រុមហ៊ុនត្រូវយកឯកសារច្បាប់ដើមមកតម្កល់នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មមានដូចខាងក្រោម៖
- លិខិតស្នើសុំធ្វើការផ្លាស់ប្តូរកែប្រែច្បាប់ដើម ចំនួន (២ ច្បាប់)
- កំណត់ហេតុអង្គប្រជុំ ឬសេចក្តីសម្រេចរបស់ម្ចាស់ហ៊ុនច្បាប់ដើម ចំនួន (២ ច្បាប់)
- ក្នុងករណីម្ចាស់ហ៊ុនជានីតិបុគ្គល សាមីក្រុមហ៊ុនត្រូវតម្កល់ឯកសារដូចខាងក្រោម៖
  - ច្បាប់ចម្លងឯកសារគតិយុត្ត នៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើម (លក្ខន្តិកៈ និងវិញ្ញាបនបត្ររបស់ក្រុមហ៊ុន) និងសេចក្តីសម្រេចក្នុងការទិញភាគហ៊ុន និងការតែងតាំងអ្នកតំណាង (សម្រាប់ម្ចាស់ហ៊ុនថ្មីជានីតិបុគ្គល) បញ្ជាក់ដោយសារការីនៃព្រះរាជាណាចក្រកម្ពុជា ឬស្ថានទូត ឬស្ថានកុងស៊ុល ឬសភាពាណិជ្ជកម្មបរទេស ដែលទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម
  - សេចក្តីសម្រេចក្នុងការផ្ទេរ ឬការលក់ភាគហ៊ុន បញ្ជាក់ដោយសារការីនៃព្រះរាជាណាចក្រកម្ពុជា ឬស្ថានទូត ឬស្ថានកុងស៊ុល ឬសភាពាណិជ្ជកម្មបរទេស ដែលទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម ឬតាមរយៈការស្នើសុំបំពេញនីតិវិធីផ្ទេរ ឬលក់ភាគហ៊ុនតាមប្រព័ន្ធអនឡាញ នៅចំពោះមុខមន្ត្រីចុះបញ្ជីនៃក្រសួងពាណិជ្ជកម្ម (សម្រាប់ការផ្ទេរ ឬលក់ភាគហ៊ុនម្ចាស់ហ៊ុនជានីតិបុគ្គល)
- លក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន (ក្នុងករណីមានការកែប្រែ) ចំនួន (២ ច្បាប់)។

**ប្រការ១៤ ._**

**សំណុំឯកសារដែលត្រូវភ្ជាប់សម្រាប់ការកែប្រែសាខាក្រុមហ៊ុនក្នុងស្រុក៖**
- សំណើស្នើសុំផ្លាស់ប្តូរកែប្រែច្បាប់ដើម ចំនួន (១ ច្បាប់)
- លិខិតប្រគល់សិទ្ធិ ចំនួន (១ ច្បាប់)
- អត្តសញ្ញាណប័ណ្ណអ្នកទទួលសិទ្ធិដែលមានចុះហត្ថលេខា ចំនួន (១ ច្បាប់)
- លិខិតគោលការណ៍ ឬលិខិតអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច (ប្រសិនបើមាន)។

**ប្រការ១៥ ._**

**សំណុំឯកសារដែលត្រូវភ្ជាប់សម្រាប់ការបិទសាខាក្រុមហ៊ុនក្នុងស្រុក (ទម្រង់ជាក្រដាសស្នាម)៖**
- ច្បាប់ចម្លងប័ណ្ណពន្ធប៉ាតង់ឆ្នាំចុងក្រោយ ចំនួន (១ ច្បាប់)



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីមែល៖ cabinet.info@moc.gov.kh

- សេចក្ដីសម្រេចរបស់អភិបាលម្នាក់ក្នុងការបិទសាខាក្រុមហ៊ុនក្នុងស្រុក
- លិខិតគោលការណ៍ ឬលិខិតអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច (ប្រសិនបើមាន)។

**ប្រការ១៦ ._**

ពាណិជ្ជករ ម្ចាស់ហ៊ុន ឬអភិបាលត្រូវធានាអះអាងចំពោះរាល់ព័ត៌មានសម្រាប់ការស្នើសុំចុះបញ្ជីកែប្រែក្នុងបញ្ជីពាណិជ្ជកម្ម និងឯកសារតម្រូវដែលខ្លួនបានបំពេញ និងបញ្ចូលតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ជាទម្រង់អេឡិចត្រូនិក រួមបញ្ចូលទាំងហត្ថលេខាឌីជីថល ដែលអនុលោមស្របតាមបទប្បញ្ញត្តិជាធរមាន (ប្រសិនបើមាន) ថាពិតជាព័ត៌មាន ឯកសារត្រឹមត្រូវ និងមិនក្លែងបន្លំ។

ប្រសិនបើមន្ត្រីចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្មរកឃើញថា ព័ត៌មាននិងឯកសារមិនត្រឹមត្រូវ ឬមានការក្លែងបន្លំ ក្រសួងពាណិជ្ជកម្មនឹងចាត់វិធានការតាមមាត្រា២៦ ថ្មី(ពីរ) នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ហើយពាណិជ្ជករ សហកម្មសិទ្ធិករ ស្ថាបនិក ម្ចាស់ហ៊ុន ឬអភិបាលនោះ ត្រូវទទួលទោសដូចមានកំណត់ក្នុងមាត្រា៤៣ នៃច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ព្រមទាំងច្បាប់ពាក់ព័ន្ធដទៃទៀតជាធរមាន។

## ជំពូកទី៦
## នីតិវិធីនៃការចុះឈ្មោះឡើងវិញក្នុងបញ្ជីពាណិជ្ជកម្ម

**ប្រការ១៧ ._**

រាល់ពាណិជ្ជករ និងក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយ ដែលមានគ្រឹះស្ថាន សាខា ការិយាល័យតំណាង បុត្រសម្ព័ន្ធ ឬទីភ្នាក់ងាររបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលពុំទាន់បានចុះឈ្មោះឡើងវិញក្នុងបញ្ជីពាណិជ្ជកម្មនៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួងពាណិជ្ជកម្ម ឬមានបំណងចង់ចុះឈ្មោះកែប្រែទម្រង់អាជីវកម្ម ដើម្បីចុះឈ្មោះថ្មីក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម ត្រូវបានអនុញ្ញាតឱ្យបន្តនីតិវិធីចុះបញ្ជីស្របតាមនីតិវិធីដូចដែលបានចែងក្នុងជំពូកទី៥ ការចុះបញ្ជីកែប្រែ នៃប្រកាសនេះ។

ពាណិជ្ជករ ម្ចាស់ហ៊ុន ឬអភិបាលត្រូវធានាអះអាងចំពោះរាល់ព័ត៌មានសម្រាប់ការស្នើសុំចុះឈ្មោះឡើងវិញក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួងពាណិជ្ជកម្ម រួមបញ្ចូលទាំងហត្ថលេខាឌីជីថល ដែលអនុលោមស្របតាមបទប្បញ្ញត្តិជាធរមាន (ប្រសិនបើមាន) ថាពិតជាព័ត៌មាន ឯកសារត្រឹមត្រូវ និងមិនក្លែងបន្លំ។

## ជំពូកទី៧
## ការរំលាយ និងលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម

**ប្រការ១៨ ._**

ចំពោះក្រុមហ៊ុន សហគ្រាស ដែលបានបំពេញកាតព្វកិច្ចបំណុលពន្ធតាមរយៈសវនកម្មជម្រះបញ្ជីពីអគ្គនាយកដ្ឋានពន្ធដារ ហើយទទួលបានលិខិតបញ្ជាក់ស្ដីពីការបិទក្រុមហ៊ុនជាស្ថាពររួចរាល់។ ក្រុមហ៊ុន សហគ្រាសអាចស្នើសុំបន្តនីតិវិធីរំលាយ និងលុបឈ្មោះក្រុមហ៊ុន សហគ្រាស មកក្រសួងពាណិជ្ជកម្មបាន ពីគ្រប់ទីកន្លែងតាមរយៈគេហទំព័រ www.businessregistration.moc.gov.kh ។

តារាងបង្ហាញលំហូរនៃនីតិវិធីចុះបញ្ជីរំលាយ និងលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម ដូចមានជូនភ្ជាប់ក្នុង**ឧបសម្ព័ន្ធទី៤** នៃប្រកាសនេះ។

**ប្រការ១៩ ._**

សំណុំឯកសារស្ដីពីសំណើសុំប្រកាសពីបំណងក្នុងការជម្រះបញ្ជី ឬរំលាយក្រុមហ៊ុន សហគ្រាស មានដូចខាងក្រោម៖

១. សំណើស្នើសុំ ចំនួន (១ ច្បាប់)
២. សេចក្ដីសម្រេចសមូហភាពរបស់ម្ចាស់ហ៊ុន ចំនួន (១ ច្បាប់)
៣. លិខិតបញ្ជាក់ស្ថានភាពសារពើពន្ធរបស់ក្រុមហ៊ុន ចំនួន (១ ច្បាប់)
៤. លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ (គិតត្រឹមកាលបរិច្ឆេទបញ្ឈប់អាជីវកម្មជាស្ថាពរ) ចំនួន (១ ច្បាប់)។

សំណុំឯកសារចុះបញ្ជីលើការរំលាយ និងលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម មានដូចខាងក្រោម៖

១. សំណើស្នើសុំ ចំនួន (១ ច្បាប់)
២. សេចក្ដីសម្រេចសមូហភាពរបស់ម្ចាស់ហ៊ុន ចំនួន (១ ច្បាប់)

៣. លិខិតបញ្ជាក់ស្ថានភាពសារពើពន្ធរបស់ក្រុមហ៊ុន ចំនួន (១ ច្បាប់)
៤. របាយការណ៍ស្តីពីការជម្រះបញ្ជី រំលាយក្រុមហ៊ុន ចំនួន (១ ច្បាប់)
៥. វិក្កយបត្របង់ពន្ធបន្ថែម (ប្រសិនបើមានការពិន័យនៅចំណុចទី៤) ចំនួន (១ ច្បាប់)
៦. របាយការណ៍បិទបញ្ជីប្រចាំឆ្នាំ (ឆ្នាំចុងក្រោយ) ចំនួន (១ ច្បាប់)
៧. លិខិតតែងតាំងសវនករ ចំនួន (១ ច្បាប់)
- សវនករ ត្រូវតែជារូបវន្តបុគ្គល ឬនីតិបុគ្គល ដែលទទួលបានអាជ្ញាប័ណ្ណគណនេយ្យ និង/ឬសវនកម្ម ពីនិយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

៨. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនសវនករ ចំនួន (១ ច្បាប់)។

ពាណិជ្ជករ ម្ចាស់ហ៊ុន ឬអភិបាលត្រូវធានាអះអាងចំពោះរាល់ព័ត៌មាន សម្រាប់ការស្នើសុំរំលាយ និងលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម ឯកសារតម្រូវដែលខ្លួនបានបំពេញ និងបញ្ចូលតាមថ្នាលបច្ចេកវិទ្យាព័ត៌មានជាទម្រង់អេឡិចត្រូនិក រួមបញ្ចូលទាំងហត្ថលេខាឌីជីថល ដែលអនុលោមស្របតាមបទប្បញ្ញត្តិជាធរមាន (ប្រសិនបើមាន) ថាពិតជាព័ត៌មាន ឯកសារត្រឹមត្រូវ និងមិនក្លែងបន្លំ។

## ជំពូកទី៨
## ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ

**ប្រការ២០.-**

រាល់ក្រុមហ៊ុន សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងក្រុមហ៊ុនបរទេស ដែលបានចុះបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម មានកាតព្វកិច្ចតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ទាក់ទងទៅនឹងស្ថានភាពក្រុមហ៊ុន សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងក្រុមហ៊ុនបរទេស។

ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ត្រូវធ្វើតាមប្រព័ន្ធស្វ័យប្រវត្តកម្ម របស់ក្រសួងពាណិជ្ជកម្ម តាមរយៈគេហទំព័រ www.businessregistration.moc.gov.kh ។

**ប្រការ២១.-**

ព័ត៌មាន និងសំណុំឯកសារសម្រាប់ការតម្កល់ប្រតិវេទន៍ ដែលត្រូវបញ្ចូលនៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួងពាណិជ្ជកម្ម ក្នុងទម្រង់អេឡិចត្រូនិក មានដូចខាងក្រោម៖

ក. ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ សម្រាប់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនសហកម្មសិទ្ធិ សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងក្រុមហ៊ុនបរទេស៖
១. លេខអត្តសញ្ញាណកម្មសារពើពន្ធ
២. កាលបរិច្ឆេទចុះបញ្ជីសារពើពន្ធ
៣. ប័ណ្ណពន្ធប៉ាតង់នៃឆ្នាំដែលត្រូវប្រកាសប្រតិវេទន៍ សម្រាប់រាល់សកម្មភាពអាជីវកម្មដែលកំពុងមានប្រតិបត្តិការ
៤. ចំនួនបុគ្គលិក និងឯកសារភ្ជាប់ ស្តីពីតួនាទីនិយោជិកជាក់ស្តែង
៥. អ៊ីមែល និងលេខទូរសព្ទក្រុមហ៊ុន ដែលកំពុងប្រើប្រាស់

ខ. ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ សម្រាប់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត៖
១. លេខអត្តសញ្ញាណកម្មសារពើពន្ធ
២. កាលបរិច្ឆេទចុះបញ្ជីសារពើពន្ធ
៣. ប័ណ្ណពន្ធប៉ាតង់នៃឆ្នាំដែលត្រូវប្រកាសប្រតិវេទន៍ សម្រាប់រាល់សកម្មភាពអាជីវកម្មដែលកំពុងមានប្រតិបត្តិការ
៤. ចំនួនបុគ្គលិក និងឯកសារភ្ជាប់ស្តីពីតួនាទីនិយោជិក
៥. អ៊ីមែល និងលេខទូរសព្ទក្រុមហ៊ុនដែលកំពុងប្រើប្រាស់
៦. របាយការណ៍ហិរញ្ញវត្ថុ និងបញ្ជីម្ចាស់ហ៊ុន។



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីមែល៖ cabinet.info@moc.gov.kh

**ប្រការ២២ ._**

រាល់បណ្តាក្រុមហ៊ុន សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងនៃក្រុមហ៊ុនបរទេស ត្រូវបានកំណត់ឱ្យបំពេញកាតព្វកិច្ចក្នុងការតម្កល់ប្រតិវេទន៍ជារៀងរាល់ឆ្នាំ។ ក្រុមហ៊ុន សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងនៃក្រុមហ៊ុនបរទេស តម្រូវឱ្យតម្កល់ប្រតិវេទន៍ក្នុងអំឡុងពេល មុន ៣ (បី) ខែ នៃថ្ងៃខួបកាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្មរបស់ខ្លួននីមួយៗ។

ក្នុងករណីក្រុមហ៊ុន សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងនៃក្រុមហ៊ុនបរទេស ខកខានមិនបានបំពេញកាតព្វកិច្ចតម្កល់ប្រតិវេទន៍ក្នុងរយៈពេលដែលបានកំណត់ខាងលើ ក្រសួងនឹងអនុគ្រោះដោយទុករយៈពេលចំនួន ១៥ (ដប់ប្រាំ) ថ្ងៃបន្ថែមទៀត សម្រាប់ការតម្កល់ប្រតិវេទន៍។

ក្នុងករណីក្រុមហ៊ុន សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងនៃក្រុមហ៊ុនបរទេស ខកខានពុំបានតម្កល់ប្រតិវេទន៍ក្នុងអំឡុងពេលដូចកំណត់ខាងលើនេះ នឹងត្រូវទទួលការពិន័យដូចមានកំណត់ដោយច្បាប់ និងចែងក្នុងប្រការ២៣ នៃប្រកាសនេះ។

**ប្រការ២៣ ._**

ក្រុមហ៊ុន សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងក្រុមហ៊ុនបរទេសទាំងឡាយណា ដែលខកខានមិនបានតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំត្រឹមថ្ងៃផុតកំណត់ នឹងត្រូវទទួលការផាកពិន័យជាទឹកប្រាក់ចំនួន ២ ០០០ ០០០ (ពីរលាន) រៀល។

ក្នុងករណីក្រុមហ៊ុន សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងក្រុមហ៊ុនបរទេស ដែលខកខានមិនបានតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំចាប់ពី១ (មួយ) ឆ្នាំឡើងទៅនឹងត្រូវបង់ប្រាក់ពិន័យ ព្រមទាំងបង់កម្រៃសេវាប្រតិវេទន៍ប្រចាំឆ្នាំទៅតាមចំនួនឆ្នាំដែលខកខាន។

ក្នុងករណីក្រុមហ៊ុន សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងក្រុមហ៊ុនបរទេស ខកខានមិនបានតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំចាប់ពី ៣ (បី) ឆ្នាំជាប់គ្នា នឹងត្រូវចាត់ទុកជាក្រុមហ៊ុនអកម្ម។

ម្ចាស់ហ៊ុន និងអភិបាលនៃក្រុមហ៊ុនអកម្ម ត្រូវដាក់នៅក្នុងបញ្ជីប្រុងប្រយ័ត្ន ដែលមិនអនុញ្ញាតឱ្យទទួលបាននូវការបម្រើសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម រួមមាន ការស្នើសុំចុះបញ្ជីបង្កើតក្រុមហ៊ុនពាណិជ្ជកម្ម ការស្នើសុំចុះបញ្ជីនូវរាល់ការផ្លាស់ប្តូរ និងកែប្រែផ្សេងៗរបស់ក្រុមហ៊ុន។

ក្រុមហ៊ុនអកម្ម អាចជាកម្មវត្ថុក្នុងការបន្តនីតិវិធីលើការរំលាយ និងលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្មតាមច្បាប់ជាធរមាន បន្ទាប់ពីបានបំពេញកាតព្វកិច្ចបំណុលពន្ធតាមរយៈសវនកម្មជម្រះបញ្ជីពីអគ្គនាយកដ្ឋានពន្ធដារ ហើយទទួលបានលិខិតបញ្ជាក់ស្តីពីការបិទក្រុមហ៊ុនជាស្ថាពររួចរាល់។

## ជំពូកទី៩
## លេខាធិការក្រុមហ៊ុន

**ប្រការ២៤ ._**

លេខាធិការក្រុមហ៊ុន សំដៅដល់រូបវន្តបុគ្គលដែលត្រូវបានចាត់តាំងដោយក្រុមហ៊ុនមូលធន ហើយមានសិទ្ធិក្នុងការទទួល និងរក្សាទុកឯកសារដែលពាក់ព័ន្ធដល់កិច្ចការរបស់ក្រុមហ៊ុន។

ក្រុមហ៊ុនមូលធន ត្រូវតែងតាំងលេខាធិការក្រុមហ៊ុនម្នាក់ ឬច្រើននាក់ ក្នុងរយៈពេល ៣ (បី) ខែ រាប់គិតចាប់ពីថ្ងៃចុះបញ្ជីពាណិជ្ជកម្ម និងត្រូវផ្តល់ដល់មន្ត្រីចុះបញ្ជីនូវឈ្មោះរបស់លេខាធិការក្រុមហ៊ុននោះ។

លេខាធិការក្រុមហ៊ុន ត្រូវបានទទួលស្គាល់ដោយស្របច្បាប់ និងមិនមានរយៈពេលកំណត់ឡើយ។ ចំពោះលេខាធិការក្រុមហ៊ុនជានីតិបុគ្គល រយៈពេលនៃការទទួលស្គាល់នេះក៏គ្មានរយៈពេលកំណត់ផងដែរ ដរាបណានីតិបុគ្គលនោះនៅតែមានបុគ្គលភាពគតិយុត្ត។

**ប្រការ២៥ ._**

**ក. ករណីលេខាធិការក្រុមហ៊ុន ជានីតិបុគ្គល ត្រូវបំពេញលក្ខខណ្ឌគុណវុឌ្ឍិ ដូចខាងក្រោម៖**

- ជាក្រុមហ៊ុនដែលបានចុះបញ្ជីស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ដែលមានអាជីវកម្មជាអ្នកផ្តល់សេវាកម្មលេខាធិការក្រុមហ៊ុន រួមមាន ក្រុមហ៊ុនមេធាវី ការិយាល័យមេធាវី ក្រុមហ៊ុនសវនកម្ម ក្រុមហ៊ុនគណនេយ្យ ឬក្រុមហ៊ុនដទៃទៀតដែលបម្រើសេវាកម្មប្រហាក់ប្រហែល

- ទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈលេខាធិការក្រុមហ៊ុនពីក្រសួងពាណិជ្ជកម្ម
- ទទួលបាននីតិសម្បទាជាលេខាធិការក្រុមហ៊ុនពីក្រសួងពាណិជ្ជកម្ម
- មានបុគ្គលិកជាលេខាធិការក្រុមហ៊ុនឈរឈ្មោះតំណាង ទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម
- បង់ប្រាក់តម្កល់ ជានាកាតព្វកិច្ចចំនួន ៤០ ០០០ ០០០ (សែសិបលាន) រៀល។

**ខ. ក្នុងករណីលេខាធិការក្រុមហ៊ុន ជារូបវន្តបុគ្គល ត្រូវបំពេញលក្ខខណ្ឌគុណវុឌ្ឍិ ដូចខាងក្រោម៖**

- ត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ ឬខ្ពស់ជាងនេះទាក់ទងនឹងផ្នែកច្បាប់ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ពាណិជ្ជកម្ម គណនេយ្យ ឬជំនាញប្រហាក់ប្រហែល
- មានបទពិសោធការងារផ្នែកច្បាប់ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ពាណិជ្ជកម្ម គណនេយ្យ ឬជំនាញប្រហាក់ប្រហែល យ៉ាងតិច ២ (ពីរ) ឆ្នាំ
- មានទីលំនៅអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជា
- ទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈលេខាធិការក្រុមហ៊ុនពីក្រសួងពាណិជ្ជកម្ម
- ទទួលបាននីតិសម្បទាជាលេខាធិការក្រុមហ៊ុនពីក្រសួងពាណិជ្ជកម្ម
- បង់ប្រាក់តម្កល់ ជានាកាតព្វកិច្ចចំនួន ៤ ០០០ ០០០ (បួនលាន) រៀល។

**គ. វគ្គបណ្តុះបណ្តាល**

វគ្គបណ្តុះបណ្តាលលេខាធិការក្រុមហ៊ុន នឹងត្រូវរៀបចំឡើង ១(មួយ)ឆ្នាំម្តង និងបែងចែកជាវគ្គបណ្តុះបណ្តាលបឋម (វគ្គវិក្រឹតការ) និងវគ្គបណ្តុះបណ្តាលបន្តបន្ទាប់ (វគ្គសុក្រឹតការ)។ កម្មវិធីបណ្តុះបណ្តាលនេះត្រូវអនុលោមតាមស្តង់ដាលេខាធិការក្រុមហ៊ុននៃបណ្តាប្រទេសធំៗ ទន្ទឹមនេះត្រូវសហការរៀបចំដោយបណ្ឌិត្យសភា និងវិទ្យាស្ថាន និងវាគ្មិនបរទេសដែលមានបទពិសោធលើការអនុវត្តការងារលេខាធិការក្រុមហ៊ុន។

ក្រោយពីឆ្លងកាត់វគ្គបណ្តុះបណ្តាល និងជាប់ជាស្ថាពរក្នុងការប្រឡងជ្រើសរើសលេខាធិការក្រុមហ៊ុន បេក្ខភាពត្រូវស្នើសុំនីតិសម្បទាជាលេខាធិការក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម។ ក្រសួងពាណិជ្ជកម្មនឹងផ្តល់ជូនប័ណ្ណសម្គាល់ និងលេខកូដសម្គាល់ទៅកាន់លេខាធិការក្រុមហ៊ុននីមួយៗ ដែលមានសុពលភាពចំនួន ៣ (បី) ឆ្នាំ។

**ប្រការ២៦ _**

លេខាធិការក្រុមហ៊ុន មានកាតព្វកិច្ច និងតួនាទី ដូចខាងក្រោម៖

- រៀបចំរបៀបវារៈនៃកិច្ចប្រជុំ និងចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល កិច្ចប្រជុំមហាសន្និបាតម្ចាស់ហ៊ុន
- ធ្វើកំណត់ហេតុលើសេចក្តីសម្រេចរបស់ម្ចាស់ហ៊ុន និងក្រុមប្រឹក្សាភិបាល កំណត់ហេតុនៃសន្និបាតម្ចាស់ហ៊ុន និងសន្និបាតក្រុមប្រឹក្សាភិបាល
- រក្សាទុកបញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុរបស់ក្រុមហ៊ុនដោយប្រុងប្រយ័ត្ន
- ទទួលដីកាអញ្ជើញ ដីកាកោះពីតុលាការ តំណាងឱ្យក្រុមហ៊ុន
- ប្រគល់ និងទទួលរាល់លិខិតផ្លូវការនានា និងឯកសារទាំងឡាយដែលតម្រូវដោយច្បាប់ តំណាងឱ្យក្រុមហ៊ុន
- ពិនិត្យ និងសម្រង់គ្រប់ឯកសារដែលបានចែងរបស់ក្រុមហ៊ុន ក្នុងម៉ោងធ្វើការធម្មតា ដោយមិនគិតថ្លៃ
- ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ នៅក្នុងម៉ោងធ្វើការធម្មតារបស់ក្រុមហ៊ុន និងអាចដកស្រង់យករបាយ-ការណ៍នោះ
- ផ្តល់ព័ត៌មាន ការបកស្រាយបំភ្លឺ និងបញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុទាំងឡាយ តាមការស្នើសុំរបស់សវនករក្រុមហ៊ុន
- ធ្វើលិខិតស្នាម ឬកិច្ចសន្យា ក្នុងនាមក្រុមហ៊ុន ទោះបីគ្មានត្រាសម្គាល់របស់ក្រុមហ៊ុន
- រៀបចំកិច្ចការរវាងម្ចាស់ហ៊ុន និងម្ចាស់ហ៊ុន និងក្រុមប្រឹក្សាភិបាល រួមទាំងកិច្ចការទំនាក់ទំនងរវាងក្រុមហ៊ុន និងវិនិយោគិនថ្មីៗ
- ធ្វើបច្ចុប្បន្នកម្មនៃការវិវត្តរបស់ច្បាប់ បទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងអាជីវកម្ម និងកាតព្វកិច្ច ដើម្បីធានាបាននូវអនុលោមភាពរបស់ក្រុមហ៊ុន និងអភិបាលកិច្ចក្រុមហ៊ុន



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីមែល៖ cabinet.info@moc.gov.kh

- សម្របសម្រួលការប្រាស្រ័យទាក់ទងរវាងក្រុមប្រឹក្សាភិបាល និងម្ចាស់ហ៊ុន
- សម្របសម្រួលការប្រាស្រ័យទាក់ទងរវាងក្រុមហ៊ុន និងក្រសួង-ស្ថាប័នមានសមត្ថកិច្ច។

**ប្រការ២៧.-**

ការលុបចោលនីតិសម្បទាជាលេខាធិការក្រុមហ៊ុន ត្រូវបានកំណត់ដូចខាងក្រោម៖

- សុំបញ្ចប់ការទទួលស្គាល់ជាលេខាធិការក្រុមហ៊ុនដោយខ្លួនឯង
- ទទួលបាននីតិសម្បទាជាលេខាធិការក្រុមហ៊ុន ដោយមធ្យោបាយក្លែងបន្លំណាមួយ
- លែងមានទីលំនៅអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្ម ឬការងារ ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា
- ធ្វើឱ្យខូចប្រយោជន៍ធ្ងន់ធ្ងរដល់ក្រុមហ៊ុន ឬបុគ្គលពាក់ព័ន្ធ
- បាត់បង់សមត្ថភាព ឬទទួលមរណភាព។

**ប្រការ២៨.-**

លេខាធិការក្រុមហ៊ុនទាំងឡាយដែលខកខានក្នុងការបំពេញកាតព្វកិច្ច និងតួនាទីរបស់ខ្លួនដោយពុំមានមូលហេតុត្រឹមត្រូវនឹងត្រូវទទួលខុសត្រូវផ្នែកទណ្ឌកម្មរដ្ឋបាលនៅចំពោះមុខក្រសួងពាណិជ្ជកម្ម និងទទួលខុសត្រូវផ្នែករដ្ឋប្បវេណីចំពោះបុគ្គលពាក់ព័ន្ធទាំងអស់។

## ជំពូកទី១០
## ការទទួលពាក្យបណ្តឹង
## នៅក្នុងសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម

**ប្រការ២៩.-**

ប្រសិនបើមានការបារម្ភថានឹងមានការខូចខាតធ្ងន់ធ្ងរ បាត់បង់ផលប្រយោជន៍ ឬការបំពានលើសិទ្ធិ បុគ្គលស្នើសុំអាចដាក់ពាក្យមកកាន់ក្រសួងពាណិជ្ជកម្ម។ ពាក្យបណ្តឹងបែងចែកជាពីរ គឺពាក្យបណ្តឹងទូទៅ និងពាក្យបណ្តឹងហាមឃាត់ការផ្ទេរភាគហ៊ុន ឬការចុះបញ្ជីកែប្រែណាមួយ។

ចំពោះពាក្យបណ្តឹងហាមឃាត់ការផ្ទេរភាគហ៊ុន ឬការចុះបញ្ជីកែប្រែណាមួយ អាចធ្វើឡើងដោយម្ចាស់ហ៊ុនណាមួយនៅក្នុងក្រុមហ៊ុន ដើម្បីធ្វើការទប់ស្កាត់នូវរាល់ការផ្ទេរភាគហ៊ុន ឬការកែប្រែណាមួយដោយយោងលើដីកាសម្រេចរក្សាការពារ ដីកាសម្រេចបើអូសជាបណ្តោះអាសន្ន លិខិតអនុវត្តនានារបស់ស្ថាប័នមានសមត្ថកិច្ច ឬបណ្តឹងជាលាយលក្ខណ៍អក្សរ។ បណ្តឹងទាំងនេះត្រូវបង់កម្រៃសេវាសាធារណៈតាមបទប្បញ្ញត្តិជាធរមាន។ ករណីរកឃើញថាបណ្តឹងមានមូលហេតុសមស្រប ក្រសួងពាណិជ្ជកម្មនឹងសម្រេចទប់ស្កាត់ការផ្ទេរភាគហ៊ុន ឬការស្នើសុំចុះបញ្ជីកែប្រែណាមួយ ដោយដាក់ក្នុងបញ្ជីប្រុងប្រយ័ត្នតាមពាក្យស្នើសុំ។

**ប្រការ៣០.-**

បុគ្គលស្នើសុំ ត្រូវបំពេញបែបបទដាក់ពាក្យស្នើសុំ ដូចខាងក្រោម៖

១. ត្រូវបំពេញ និងដាក់ពាក្យស្នើសុំ នៅក្រសួងពាណិជ្ជកម្ម

២. រាល់ការដាក់ពាក្យស្នើសុំ ដូចបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ ត្រូវភ្ជាប់មកជាមួយនូវ៖

   ក. សំអាងហេតុ

   ខ. កម្មវត្ថុនៃការស្នើសុំ

   គ. លិខិតធានាអះអាងពីភាពត្រឹមត្រូវនៃភស្តុតាង

   ឃ. ឯកសារគាំទ្រ

៣. ត្រូវបង់កម្រៃសេវាសាធារណៈ។

**ប្រការ៣១.-**

បន្ទាប់ពីទទួលបានពាក្យស្នើសុំដូចខាងលើ ក្រសួងពាណិជ្ជកម្មមានកាតព្វកិច្ចត្រូវ៖



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh

១. ចេញលិខិតបញ្ជាក់ទទួលពាក្យស្នើសុំបន្ទាប់ពីបានទទួលពាក្យស្នើសុំ និងពិនិត្យឃើញថាបុគ្គលស្នើសុំបានបំពេញសំណុំបែបបទ និងឯកសារតម្រូវគ្រប់គ្រាន់

២. រៀបចំដាក់បញ្ចូលពាក្យស្នើសុំទៅក្នុងបញ្ជីពាក្យស្នើសុំ និងបញ្ជូនពាក្យស្នើសុំទៅកាន់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងពាណិជ្ជកម្ម ទៅតាមកម្មវត្ថុនៃការស្នើសុំ

៣. សម្របសម្រួល និងសហការជាមួយអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងពាណិជ្ជកម្ម ដើម្បីពិនិត្យ និងដោះស្រាយកម្មវត្ថុនៃការស្នើសុំស្របតាមតួនាទី ភារកិច្ចរៀងៗខ្លួន

៤. ជូនដំណឹងទៅកាន់បុគ្គលស្នើសុំ បន្ទាប់ពីទទួលបានលទ្ធផលនៃការដោះស្រាយពាក្យស្នើសុំ

៥. រៀបចំរបាយការណ៍បញ្ជីពាក្យស្នើសុំ របាយការណ៍ស្ថានភាព និងរបាយការណ៍លទ្ធផលដំណោះស្រាយលើពាក្យស្នើសុំដែលបានទទួល។

## ជំពូកទី១១
## កម្រៃសេវា

**ប្រការ៣២ .-**

ការទូទាត់កម្រៃសេវាដែលត្រូវបង់ចូលជាថវិកាជាតិ ត្រូវធ្វើតាមប្រព័ន្ធអេឡិចត្រូនិករបស់ធនាគារ ផ្អែកតាមការកំណត់ក្នុងប្រកាសអន្តរក្រសួងលេខ៣១៥ សហវ.ប្រក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ឬលិខិតបទដ្ឋានពាក់ព័ន្ធជាធរមាន ឬលិខិតបទដ្ឋានដែលនឹងត្រូវបានធ្វើវិសោធនកម្ម។

ក្រុមហ៊ុនអាចរក្សាទុកនូវបង្កាន់ដៃបង់ប្រាក់ ដែលចេញដោយប្រព័ន្ធស្វ័យប្រវត្តកម្ម ដើម្បីជាភស្តុតាងបញ្ជាក់ថា ពិតជាបានធ្វើការទូទាត់ប្រាក់រួចពិតមែន។

ក្នុងករណីពាណិជ្ជករ សហកម្មសិទ្ធិករ ស្ថាបនិក ម្ចាស់ហ៊ុន ឬអភិបាល អញ្ជើញមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ដើម្បីស្នើឱ្យមន្ត្រីចុះបញ្ជីជួយបំពេញនូវព័ត៌មាន និងបញ្ចូលលក្ខខណ្ឌតម្រូវក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មជំនួសការទូទាត់កម្រៃសេវា ត្រូវធ្វើដោយផ្ទាល់នៅបញ្ជរបង់កម្រៃសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

## ជំពូកទី១២
## អវសានប្បញ្ញត្តិ

**ប្រការ៣៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣៤ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋាន ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ប្រធានគ្រប់អង្គភាពចំណុះក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី៨ ខែមករា ឆ្នាំ២០២៦ តទៅ។

ថ្ងៃ អង្គារ ៤ រោច ខែ មិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ២០២៥

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម និម្មល**

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៣៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh

**ឧបសម្ព័ន្ធទី១៖** តារាងបង្ហាញលំហូរនៃនីតិវិធីចុះបញ្ជីពាណិជ្ជកម្ម

ភ្ជាប់នឹងប្រកាសលេខ ១១៧ ពណ.ចបព.ប្រក ចុះថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ២០២៥

ស្តីពីការធ្វើសាមញ្ញកម្មនៃការងារចុះបញ្ជីពាណិជ្ជកម្ម



**ឧបសម្ព័ន្ធទី២៖** តារាងបង្ហាញលំហូរនៃនីតិវិធីចុះបញ្ជីបង្កើតសាខាក្រុមហ៊ុនក្នុងស្រុក
ភ្ជាប់នឹងប្រកាសលេខ ១១៧ ពណ.ចបព.ប្រក ចុះថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ២០២៥
ស្តីពីការធ្វើសាមញ្ញកម្មនៃការងារចុះបញ្ជីពាណិជ្ជកម្ម



**ឧបសម្ព័ន្ធទី៣៖** តារាងបង្ហាញលំហូរនៃនីតិវិធីចុះបញ្ជីកែប្រែ
ភ្ជាប់នឹងប្រកាសលេខ ១១៧៣.៣.ឧបព.ប្រក ចុះថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ២០២៥
ស្ដីពីការធ្វើសាមញ្ញកម្មនៃការងារចុះបញ្ជីពាណិជ្ជកម្ម



**ឧបសម្ព័ន្ធទី៤៖** តារាងបង្ហាញលំហូរនៃនីតិវិធីចុះបញ្ជីរំលាយ និងលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម
ភ្ជាប់នឹងប្រកាសលេខ ១១៧ ពណ.ចបព.ប្រក ចុះថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ២០២៥
ស្តីពីការធ្វើសាមញ្ញកម្មនៃការងារចុះបញ្ជីពាណិជ្ជកម្ម



**ឧបសម្ព័ន្ធទី៥៖** គំរូឯកសារតម្រូវ

ភ្ជាប់នឹងប្រកាសលេខ ១១៧ ពា.ណា.ឧបព.ប្រក ចុះថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ២០២៥

ស្តីពីការធ្វើសាមញ្ញកម្មនៃការងារចុះបញ្ជីពាណិជ្ជកម្ម

https://go.gov.kh/moc/jx2rav

GO.gov.KH

ទាញយកឯកសារជា PDF

https://go.gov.kh/moc/pxcjx6

GO.gov.KH

ទាញយកឯកសារជា Microsoft Word

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងពាណិជ្ជកម្ម

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សហគ្រាស **ក.ក.ក ៦.ក**

KOR.KOR.KOR CO., LTD.

## សូមគោរពជូន
## លោកជំទាវរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ពាក្យសុំកែប្រែលក្ខន្តិកៈក្រុមហ៊ុន
Application for Amendment of Articles of Incorporation

នាមត្រកូល និងនាមខ្លួន ៖ លោក **ក**

សញ្ជាតិ ៖ ខ្មែរ

អាសយដ្ឋានបច្ចុប្បន្ន ៖ លេខ១២៣ ផ្លូវលេខ១២៣ សង្កាត់១២៣ ខណ្ឌ១២៣ រាជធានីភ្នំពេញ

អត្តសញ្ញាណប័ណ្ណ ៖ ០០០០០១២៣ ចុះថ្ងៃទី ខែ ឆ្នាំ

ធ្វើក្នុងនាមជា ៖ អភិបាល □ អណត្តិគាហក □

នៃក្រុមហ៊ុន ៖ **ក.ក.ក ៦.ក**

KOR.KOR.KOR CO., LTD.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម ៖ ០០០០០១២៣ ចុះថ្ងៃទី ខែ ឆ្នាំ

លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី............ខែ .............ឆ្នាំ................ (បើមានអណត្តិគាហក) ៖ .......................................

**ដោយយោងលើ** ៖

-កំណត់ហេតុនៃអង្គប្រជុំ និងសេចក្តីសម្រេចសម្ធហាភាព

នាថ្ងៃទី ខែ ឆ្នាំ

-លក្ខន្តិកៈថ្មីក្រុមហ៊ុន ចុះហត្ថលេខា ថ្ងៃទី ខែ ឆ្នាំ

ស្នើសុំចុះបញ្ជីពាណិជ្ជកម្ម នូវការកែប្រែលក្ខន្តិកៈក្រុមហ៊ុន

**ក.ក.ក ៦.ក**

KOR.KOR.KOR CO., LTD.

តាមខ្លឹមសារដូចមានចែងខាងក្រោមនេះ ៖

១- ការបញ្ចូលសមាជិកហ៊ុនថ្មី ០២ រូប គឺ លោក **គ** និងក្រុមហ៊ុន **ចឆជ ៦.ក** តំណាងដោយលោក **ឃ**

២- ការលាលែងចេញសមាជិកហ៊ុន ០១ រូប គឺ លោក **ខ** "អភិបាលចាស់"

- ការធ្វើអនុប្បទានភាគហ៊ុនដូចតទៅ ៖

ភាគហ៊ុនចំនួន ៥០០ ភាគហ៊ុន របស់ លោក **ខ**

ផ្ទេរជូនទៅ លោក **គ** ចំនួន ២៥០ ភាគហ៊ុន និង

ផ្ទេរជូនទៅ ក្រុមហ៊ុន **ចឆជ ៦.ក** ចំនួន ២៥០ ភាគហ៊ុន

(ដូចមានតារាង ខ.១ ឧបសម្ពន្ធទី១ និងទី២ ភ្ជាប់ជាមួយនេះ)

៣- ការតែងតាំងក្រុមប្រឹក្សាភិបាលថ្មីក្រុមហ៊ុន ដូចតទៅ ៖

| | |
|---|---|
| លោក **ក** | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក **គ** | អភិបាល |
| លោក **ឃ** "តតិយជន" | អភិបាល |

៤- ការតម្កល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន

ក្រុមហ៊ុនសូមធានាអះអាងរាល់ឯកសារដែលពាក់ព័ន្ធដល់ការកែប្រែលក្ខន្តិកៈក្រុមហ៊ុននេះពិតជាត្រឹមត្រូវ មិនមានការក្លែងបន្លំលើប្រការណាមួយឡើយ នឹងសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់នូវរាល់កាតព្វកិច្ចទាំងឡាយ ដែលពាក់ព័ន្ធ និងពន្ធដារ បំណុលជាមួយរដ្ឋ និងតតិយជន ព្រមទាំងបាតុភាព ជាយថាហេតុណាមួយដែលអាចកើតចេញពីការកែប្រែលក្ខន្តិកៈក្រុមហ៊ុននេះ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោកជំទាវរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ ។

សូមលោកជំទាវរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ថ្ងៃទី ខែ ឆ្នាំ

ប្រធានក្រុមប្រឹក្សាភិបាល

(ហត្ថលេខា ត្រា និងស្នាមមេដៃស្តាំ)

**ក**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## <u>សេចក្តីសម្រេចរបស់ក្រុមហ៊ុន</u>

នាមករណ៍ក្រុមហ៊ុន ៖ **ក.ក.ក ៦.ក**

KOR.KOR.KOR CO., LTD.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម ៖ ០០០០០១២៣ ចុះថ្ងៃទី ខែ ឆ្នាំ

ទីកន្លែងចុះបញ្ជីពាណិជ្ជកម្ម ៖ នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម (ក្រសួងពាណិជ្ជកម្ម)

## កំណត់ហេតុនៃអង្គប្រជុំ និងសេចក្តីសម្រេចសមូហភាព

ឆ្នាំពីរពាន់ ខែ ថ្ងៃ វេលាម៉ោង

នៅទីស្នាក់ការក្រុមហ៊ុន **ក.ក.ក ៦.ក**

KOR.KOR.KOR CO., LTD.

មានអាសយដ្ឋាន ៖ លេខ១២៣ ផ្លូវលេខ១២៣ សង្កាត់១២៣ ខណ្ឌ១២៣ រាជធានីភ្នំពេញ

មានបើកអង្គប្រជុំវិសាមញ្ញមួយក្រោមអធិបតីភាពរបស់ លោក **ក** ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុនជាប្រធានអង្គប្រជុំ ។

**អញ្ជើញចូលរួមក្នុងអង្គប្រជុំ ៖**

លោក **ក** មានចំនួន ៥០០ ភាគហ៊ុន

លោក **ខ** មានចំនួន ៥០០ ភាគហ៊ុន

លោក **គ**

ក្រុមហ៊ុន **ចឆជ ៦.ក**

តំណាងដោយ លោក **ឃ**

**របៀបវារៈនៃអង្គប្រជុំមាន ៖**

គំរូឯកសារ

១- ការបញ្ចូលសមាជិកហ៊ុនថ្មី ០២ រូប

២- ការលាលែងចេញសមាជិកហ៊ុន ០១ រូប

- ការធ្វើអនុប្បទានភាគហ៊ុន

៣- ការតែងតាំងក្រុមប្រឹក្សាភិបាលថ្មី

៤- ការតម្កល់ទុកលក្ខន្តិក:ថ្មីរបស់ក្រុមហ៊ុន

**លទ្ធផលនៃអង្គប្រជុំ ៖**

ជាកិច្ចចាប់ផ្តើមប្រធានអង្គប្រជុំបានធ្វើការកត់សម្គាល់នូវចំនួនសមាជិកម្ចាស់ភាគហ៊ុនចាស់វត្តមានក្នុងអង្គប្រជុំមានចំនួន ០១ រូប ដែលរួមមានកាន់កាប់ភាគហ៊ុនចំនួន ១.០០០ ភាគហ៊ុន លើភាគហ៊ុនសរុប ១.០០០ ភាគហ៊ុន របស់ក្រុមហ៊ុន និងមានការចូលរួមរបស់សមាជិកថ្មីទទួលភាគហ៊ុនផ្ទេរ ។ ចំនួនសមាជិកម្ចាស់ភាគហ៊ុនចាស់វត្តមាននេះ តំណាងឱ្យចំនួនលើសពីពាក់កណ្តាល +១ នៃដើមទុនទាំងអស់របស់ក្រុមហ៊ុន ដែលជាកូរ៉ុមគ្រប់គ្រាន់សម្រាប់ធ្វើការសម្រេចបានដោយស្របច្បាប់ ។

**អង្គប្រជុំសម្រេចដូចតទៅ ៖**

## សេចក្តីសម្រេចសមូហភាព

១- យល់ព្រមលើការបញ្ចូលសមាជិកហ៊ុនថ្មី ០២ រូប គឺ លោក **គ** និងក្រុមហ៊ុន **ចឆជ ៦.ក** តំណាងដោយលោក **ឃ**

២- យល់ព្រមលើការលាលែងចេញសមាជិកហ៊ុន ០១ រូប គឺ លោក **ខ** "អភិបាលចាស់"

- ការធ្វើអនុប្បទានភាគហ៊ុនដូចតទៅ ៖

ភាគហ៊ុនចំនួន ៥០០ ភាគហ៊ុន របស់ លោក **ខ**

ផ្ទេរជូនទៅ លោក **គ** ចំនួន ២៥០ ភាគហ៊ុន និង

ផ្ទេរជូនទៅ ក្រុមហ៊ុន **ចឆជ ៦.ក** ចំនួន ២៥០ ភាគហ៊ុន

(ដូចមានតារាង ខ.១ ឧបសម្ពន្ធទី១ និងទី២ ភ្ជាប់ជាមួយនេះ)

៣- យល់ព្រមលើការតែងតាំងក្រុមប្រឹក្សាភិបាលថ្មីក្រុមហ៊ុន ដូចតទៅ ៖

| | |
|---|---|
| លោក **ក** | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក **គ** | អភិបាល |
| លោក **ឃ** "តតិយជន" | អភិបាល |

៤- យល់ព្រមលើការតម្កល់ទុកលក្ខន្តិក:ថ្មីរបស់ក្រុមហ៊ុន

អង្គប្រជុំបានចប់សព្វគ្រប់នៅថ្ងៃដដែល ។

ថ្ងៃទី ខែ ឆ្នាំ
ប្រធានក្រុមប្រឹក្សាភិបាល
(ហត្ថលេខា ត្រា និងស្នាមមេដៃស្តាំ)

**ក**

បានចូលរួម និងយល់ព្រម
(ហត្ថលេខា និងស្នាមមេដៃស្តាំ)

លោក **ខ**

លោក **គ**

ក្រុមហ៊ុន **ចឆជ ៦.ក**
តំណាងដោយលោក **ឃ**

គំរូពាក្យសុំ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមហ៊ុន ក.ក.ក ៦.ក**

KOR.KOR.KOR CO., LTD.

**សូមគោរពជូន**

**លោកជំទាវរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**កម្មវត្ថុ** ៖ សំណើសុំប្រកាសពីបំណងជម្រះបញ្ជីនិងលុបឈ្មោះក្រុមហ៊ុនពីបញ្ជីពាណិជ្ជកម្ម ។

**យោង** ៖ វិញ្ញាបនបត្រមានអត្តលេខចុះបញ្ជីពាណិជ្ជកម្មលេខ 0000000000 ចុះថ្ងៃទី ខែ ឆ្នាំ

តបតាមកម្មវត្ថុនិងយោងខាងលើ យើងខ្ញុំសូមជម្រាប **លោកជំទាវរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដោយសារទីផ្សារពុំអំណោយផល ហេតុនេះយើងខ្ញុំក៏បានស្នើសុំបិទក្រុមហ៊ុនដោយគោរពតាមបែបបទ និងនីតិវិធីច្បាប់ជាធរមាន។យើងខ្ញុំបានស្នើសុំទៅអគ្គនាយកដ្ឋានពន្ធដារ ហើយទទួលបានលិខិតបញ្ជាក់ស្ដីពីការបិទក្រុមហ៊ុនជាស្ថាពររួចរាល់ផងដែរ។ ដើម្បីអាចបន្តនីតិវិធីបិទក្រុមហ៊ុននេះ យើងខ្ញុំសុំធ្វើការប្រកាសពីការជម្រះបញ្ជី ដើម្បីរំលាយ និងលុបឈ្មោះក្រុមហ៊ុនរបស់យើងខ្ញុំពីបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មជាស្ថាពរ។

អាស្រ័យហេតុនេះ សូម **លោកជំទាវរដ្ឋមន្ត្រី** មេត្តាពិនិត្យសម្រេច លើការប្រកាសពីបំណងជម្រះបញ្ជីនិងលុបឈ្មោះក្រុមហ៊ុនពីបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុនយើងខ្ញុំដោយក្ដីអនុគ្រោះ ។

សូម **លោកជំទាវ រដ្ឋមន្ត្រី** មេត្តាទទួលនូវគោរវកិច្ចដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ ។

ថ្ងៃទី ខែ ឆ្នាំ

**ប្រធានក្រុមប្រឹក្សាភិបាល**

( ហត្ថលេខា និង ត្រា )

លោក ក

## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

*****

នាមករណ៍ក្រុមហ៊ុន : **ក.ក.ក ៦.ក**

KOR.KOR.KOR CO., LTD.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : 0000000000 ចុះថ្ងៃទី ខែ ឆ្នាំ

## <u>សេចក្តីសម្រេចសម្ងហនាព</u>

អង្គប្រជុំក្រុមប្រឹក្សាភិបាលក្រុមហ៊ុន **ក.ក.ក ៦.ក**. KOR.KOR.KOR CO., LTD. ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ 0000000000 ចុះថ្ងៃទី ខែ ឆ្នាំ មានអាសយដ្ឋាននៅលេខ ០០ ផ្លូវ ០០ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**<u>សមាសភាពក្រុមប្រឹក្សាភិបាល៖</u>**

- លោក **ក** ជាប្រធានក្រុមប្រឹក្សាភិបាល កាន់កាប់ភាគហ៊ុនចំនួន ៥១០ ភាគហ៊ុន
- លោក **ខ** ជាអភិបាល កាន់កាប់ភាគហ៊ុនចំនួន ៤៩០ ភាគហ៊ុន

## <u>សេចក្តីសម្រេចសម្ងហនាព</u>

១. សម្រេចប្រកាសពីគោលបំណងចម្រះបញ្ជី

២. សម្រេចប្រកាសពីគោលបំណងរំលាយ និងលុបឈ្មោះក្រុមហ៊ុនចេញពីបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម។

សេចក្តីសម្រេចនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃទី ខែ ឆ្នាំ

**ប្រធានក្រុមប្រឹក្សាភិបាល**

( ហត្ថលេខា និង ត្រា )

**បានអាន និង យល់ព្រម**

(ហត្ថលេខា)

**ក**

**ខ**

## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

*****

**ក្រុមហ៊ុន ក.ក.ក ៦.ក**

KKOR.KOR.KOR CO., LTD.

## សូមគោរពជូន

## លោកជំទាវរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**កម្មវត្ថុ** ៖ សំណើសុំរំលាយនិងលុបឈ្មោះក្រុមហ៊ុនពីបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

**យោង** ៖ -វិញ្ញាបនបត្រមានអត្តលេខចុះបញ្ជីពាណិជ្ជកម្មលេខ 0000000000 ចុះថ្ងៃទី ខែ ឆ្នាំ

-លិខិតបញ្ជាក់ស្ថានភាពសារពើពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ។

តបតាមកម្មវត្ថុនិងយោងខាងលើ យើងខ្ញុំសូមជម្រាប **លោកជំទាវរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដោយសារទីផ្សារពុំអំណោយផល ហេតុនេះយើងខ្ញុំក៏បានស្នើសុំបិទក្រុមហ៊ុនដោយគោរពតាមបែបបទ និងនីតិវិធីច្បាប់ជាធរមាន។យើងខ្ញុំបានស្នើសុំទៅអគ្គនាយកដ្ឋានពន្ធដារ ហើយទទួលបានលិខិតបញ្ជាក់ស្តីពីការបិទក្រុមហ៊ុនជាស្ថាពររួចរាល់ផងដែរ។ ដើម្បីអាចបន្តនីតិវិធីបិទក្រុមហ៊ុននេះ យើងខ្ញុំសុំរំលាយនិងលុបឈ្មោះក្រុមហ៊ុនរបស់យើងខ្ញុំពីបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មជាស្ថាពរ។

អាស្រ័យហេតុនេះ សូម **លោកជំទាវរដ្ឋមន្ត្រី** មេត្តាពិនិត្យសម្រេច លើការរំលាយនិងលុបឈ្មោះក្រុមហ៊ុនពីបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុនយើងខ្ញុំដោយក្តីអនុគ្រោះ ។

សូម **លោកជំទាវ រដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ ។

ថ្ងៃទី ខែ ឆ្នាំ

**ប្រធានក្រុមប្រឹក្សាភិបាល**

( ហត្ថលេខា និង ត្រា )

លោក ក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*****

នាមករណ៍ក្រុមហ៊ុន : **ក.ក.ក ឯ.ក**

KOR.KOR.KOR CO., LTD.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : 0000000000 ចុះថ្ងៃទី ខែ ឆ្នាំ

## កំណត់ហេតុអង្គប្រជុំ និងសេចក្តីសម្រេចសម្ធហភាព

ឆ្នាំពីរពាន់ ខែ ថ្ងៃទី វេលាម៉ោងប្រាំបីព្រឹក នៅទីស្នាក់ការក្រុម **ក.ក.ក ឯ.ក KOR.KOR.KOR CO., LTD.** ដែលមានអាសយដ្ឋាន លេខ ០០ ផ្លូវ ០០ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ មានបើកអង្គប្រជុំវិសាមញ្ញមួយក្រោមអធិបតីភាពរបស់ លោក ក ជាប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ជាប្រធានអង្គប្រជុំ ។

### អញ្ជើញចូលរួមក្នុងអង្គប្រជុំមាន ៖

- លោក ក ជាប្រធានក្រុមប្រឹក្សាភិបាល កាន់កាប់ភាគហ៊ុនចំនួន ៥១០ ភាគហ៊ុន
- លោក ខ ជាអភិបាល កាន់កាប់ភាគហ៊ុនចំនួន ៤៩០ ភាគហ៊ុន

### របៀបវារៈនៃអង្គប្រជុំ ៖

១- ការរំលាយក្រុមហ៊ុន និងលុបឈ្មោះក្រុមហ៊ុនចេញពីបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម

២- ការប្រគល់សិទ្ធជូនលោក ក ជាប្រធានក្រុមប្រឹក្សាភិបាលក្នុងការជម្រះបញ្ជី

៣- ការតែងតាំងសវនករ

### លទ្ធផលនៃអង្គប្រជុំ ៖

ជាកិច្ចចាប់ផ្តើម លោកស្រីប្រធានអង្គប្រជុំបានធ្វើការកត់សំគាល់នូវចំនួនសមាជិកម្ចាស់ហ៊ុនមានវត្តមានក្នុងអង្គប្រជុំមានចំនួន ០២ រូប ដែលរួមមានកាន់កាប់ភាគហ៊ុនចំនួន ១០០០ ភាគហ៊ុនលើភាគហ៊ុនសរុប ១០០០ ភាគហ៊ុនរបស់ក្រុមហ៊ុន ។ ចំនួនសមាជិកភាគហ៊ុនវត្តមាននេះ តំណាងឲ្យចំនួនលើសពីពាក់កណ្តាល +1 នៃដើមទុនទាំងអស់របស់ក្រុមហ៊ុន ដែលជាកូរ៉ុមគ្រប់គ្រាន់សម្រាប់ធ្វើសេចក្តីសម្រេចបានដោយស្របច្បាប់ ។

### អង្គប្រជុំសម្រេចដូចតទៅ ៖

១ - យល់ព្រមលើការរំលាយក្រុមហ៊ុននិងលុបឈ្មោះក្រុមហ៊ុន **ក.ក.ក ឯ.ក KOR.KOR.KOR CO., LTD.** ចេញពីបញ្ជីពាណិជ្ជកម្ម មុនកាលកំណត់ដោយមូលហេតុទីផ្សារពុំអំណោយផលចំពោះក្រុមហ៊ុន ។

២ - យល់ព្រមលើប្រគល់សិទ្ធជូន លោក **ក** ជាប្រធានក្រុមប្រឹក្សាភិបាលក្នុងការជម្រះបញ្ជី និងចេញសេចក្តីសម្រេចស្តីពីការរំលាយក្រុមហ៊ុនព្រមទាំងបំពេញបែបបទលិខិតស្នាមក្នុងការផ្សាយជាសារធារណៈ និងលុបឈ្មោះ ក្រុមហ៊ុនចេញពី បញ្ជីពាណិជ្ជកម្ម ស្របទៅតាមបទបញ្ញត្តិនៃច្បាប់។

៣ - យល់ព្រមលើការតែងតាំង លោក **ច** "តតិយជន" ជាសវនករ។

អង្គប្រជុំបានចប់សព្វគ្រប់នៅម៉ោងដប់មួយព្រឹក នាថ្ងៃដដែល ។

ថ្ងៃទី ខែ ឆ្នាំ

**ប្រធានក្រុមប្រឹក្សាភិបាល**

( ហត្ថលេខា និង ត្រា )

**ក**

**បានអាន និង យល់ព្រម**

(ហត្ថលេខា)

**ខ**

**បានអាន និង យល់ព្រម**

**សវនករ**

**ច**

គំរូឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
*****

**ក្រុមហ៊ុន ក.ក.ក ៦.ក**
KOR.KOR.KOR CO., LTD.

អាសយដ្ឋាន៖ លេខ ០០ ផ្លូវ ០០ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ

**លិខិតតែងតាំងសវនករ**

ខ្ញុំឈ្មោះ ក ប្រធានក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុន **ក.ក.ក ៦.ក KOR.KOR.KOR CO., LTD.** បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មក្រោមអត្តលេខ 0000000000 ចុះថ្ងៃទី ខែ ឆ្នាំ និងបានចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារក្រោមអត្តលេខ និងមានទីស្នាក់ការ ក្រុមហ៊ុនស្ថិតលេខ ០០ ផ្លូវ ០០ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**សូមធ្វើការតែងតាំង**

ឈ្មោះ ច ភេទ សញ្ជាតិ កាន់អត្តសញ្ញាណបណ្ណលេខ ចុះថ្ងៃទី ជាអ្នកតំណាងស្របច្បាប់ និងតែងតាំងជាសវនកររបស់ក្រុមហ៊ុនដើម្បីធ្វើការជំរះបញ្ជីដើម្បីរំលាយ ក្រុមហ៊ុន និងលុបឈ្មោះក្រុមហ៊ុនចេញពីបញ្ជីរបស់ក្រសួងពាណិជ្ជកម្ម។

អាស្រ័យហេតុនេះ សូមភាគីដែលពាក់ព័ន្ធមេត្តាទទួលស្គាល់អ្នកតំណាង និងជាសវនកររបស់ក្រុមហ៊ុន។

លិខិតផ្ទេរសិទ្ធិនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃទី...........ខែ..................ឆ្នាំ

បានអាន និងយល់ព្រម
**ទទួលមុខងារជាសវនករ**
*(ហត្ថលេខា)*

**ប្រធានក្រុមប្រឹក្សាភិបាល និងជាអ្នកប្រគល់សិទ្ធ**
*(ហត្ថលេខា និងត្រា)*

ច

ក

ក្បាលកំរុំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

* * * * *

**ក្រុមហ៊ុន ក.ក.ក ឯ.ក**
**KOR.KOR.KOR CO., LTD.**

ធ្វើនៅថ្ងៃទី ខែ ឆ្នាំ

# របាយការណ៍ស្តីពី
# ការជម្រះបញ្ជី រំលាយក្រុមហ៊ុន កខគ ឯ.ក
# ដើម្បីលុបក្រុមហ៊ុនចេញពីបញ្ជីពាណិជ្ជកម្ម

**ក្រុមហ៊ុន ក.ក.ក ឯ.ក** គឺជាក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតស្របតាមច្បាប់ និង បទដ្ឋាននានា នៅក្រសួងពាណិជ្ជកម្មក្រោមបញ្ជី 0000000000 ចុះថ្ងៃទី ខែ ឆ្នាំ និងបានចុះបញ្ជីស្ថាពរ នៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោមលេខ អត្តសញ្ញាណកម្មសារពើពន្ធ (អ.ត.ប) ដែលមានអាសយដ្ឋានចុះបញ្ជីជាគោលដើមនៅ លេខ ០០ ផ្លូវ ០០ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

យោងតាមសេចក្តីសម្រេចនិងសេចក្តីប្រកាសស្តីពីការរំលាយ **ក្រុមហ៊ុន ក.ក.ក ឯ.ក**។

យោងតាមលក្ខន្តិកៈ សមាសភាពម្ចាស់ភាគហ៊ុន ៖

- លោក **ក** ជាប្រធានក្រុមប្រឹក្សាភិបាល កាន់កាប់ភាគហ៊ុនចំនួន ៥១០ ភាគហ៊ុន
- លោក **ខ** ជាអភិបាល កាន់កាប់ភាគហ៊ុនចំនួន ៤៩០ ភាគហ៊ុន

ម្ចាស់ភាគហ៊ុនខាងលើកាន់កាប់ភាគហ៊ុន ១០០០ ភាគហ៊ុន ស្មើនឹង ៤០.០០០.០០០ រៀល ដែលក្នុងមួយភាគហ៊ុនតម្លៃ ៤០.០០០ រៀល ដែលភាគហ៊ុននេះត្រូវបង់បញ្ចូលក្នុងក្រុមហ៊ុនទាំងស្រុង និងគ្រប់ចំនួន។

ដោយពុំមានទីផ្សារសមស្រប **ក្រុមហ៊ុន ក.ក.ក ឯ.ក** សម្រេចបញ្ឈប់សកម្មភាព អាជីវកម្មរបស់ខ្លួនជាស្ថាពរមុនកាលកំណត់។

ក្រោយប្រកាសរំលាយ អាជីវកម្ម ម្ចាស់ភាគហ៊ុន សម្រេចធ្វើការបែងចែក និងចាត់ចែងទ្រព្យសម្បត្តិ និងទុនដែលនៅសល់ដូចមានក្នុងរបាយការណ៍ ហិរញ្ញវត្ថុ របស់ក្រុមហ៊ុន គិតត្រឹមតែ ថ្ងៃទី ខែ ឆ្នាំ ទៅតាម សមាមាត្រនៃភាគរយ នៃភាគហ៊ុនដែលមានចែងក្នុងលក្ខន្តិកៈ ដូចខាងក្រោម:

**១. ចំពោះ គណនី ទ្រព្យសកម្មរយៈពេលខ្លី (Current Assets) ៖**

**១.១ ចំពោះគណនីសាច់ប្រាក់នៅក្នុងបេឡានិងនៅធនាគារ (Cash on hand and in Banks) (គិតជារៀល)៖**

គណនីសាច់ប្រាក់នៅក្នុងដៃ និងនៅធនាគារ រៀល

**២ បំណុលសារពើពន្ធ ចំពោះរដ្ឋ ៖**

បន្ទាប់ពីបានដាក់លិខិត ស្នើសុំបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ ជូនអគ្គនាយកដ្ឋានពន្ធដាររួចមកក្រុមហ៊ុន បានទទួលការធ្វើសវនកម្មសារពើពន្ធរួចរាល់ និងទទួលបានលិខិតកំណត់ពន្ធឡើងវិញ តាមរយៈលិខិតជូនដំណឹងលេខ ចុះថ្ងៃទី ខែ ឆ្នាំ ដែលមិនតម្រូវអោយមានការកំណត់ពន្ធឡើងវិញទេ។

ក្រុមហ៊ុនបានធ្វើការទូទាត់រួចរាល់ តាមរយៈបង្កាន់ដៃបង់ពន្ធលេខ ក្រោយពីបានទូទាត់រួចក្រុមហ៊ុនបានទទួលលិខិតបញ្ជាក់សារពើពន្ធពីអគ្គនាយកដ្ឋានពន្ធដារជាស្ថាពរ។ ការទូទាត់ប្រាក់បំណុលពន្ធនេះ ជាបន្ទុករបស់ម្ចាស់ហ៊ុន ។

**៣. <u>បំណុលសាធារណៈ</u> ៖**

ក្រុមហ៊ុន ពុំមានជំពាក់បំណុល សាធារណៈទេ ឬ បំពុលចំពោះតតីយជន ណាមួយឡើយ ក្នុងអំឡុងពេលចាប់ផ្តើមរហូតដល់បិទអាជីវកម្ម ហើយម្ចាស់ភាគហ៊ុនខាងលើ សូមធានារាល់បំណុលទាំងឡាយ ចំពោះមុខច្បាប់ជាធរមានប្រសិនបើមានភាគីណាមួយចេញមុខបញ្ជាក់ពីបំណុលណាមួយដែលក្រុមហ៊ុនចាប់ពីថ្ងៃរំលាយរហូតដល់រយៈពេល ១០ ឆ្នាំ ខាងមុខ។

ភាគីទាំងអស់បានយល់ព្រម ធ្វើការរំលាយក្រុមហ៊ុន និងបែងចែកទ្រព្យសម្បត្តិដូចបានកំណត់តាមនីតិវិធីខាងលើ ទៅតាមសមាមាត្រ ដូចមានចែងក្នុងលក្ខន្តិកៈក្រុមហ៊ុន និងបានចុះហត្ថលេខាទទួលស្គាល់ខាងក្រោម៖

| ក | ខ |
|---|---|
| | |
| ប្រធានក្រុមប្រឹក្សាភិបាល<br>និងជាអ្នកជំរះបញ្ជី | អភិបាល |

| ច | ប្រថាប់ត្រាក្រុមហ៊ុន |
|---|---|
| | |
| សវនករ | |

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចសន្យាជួល

**កិច្ចសន្យាជួលនេះ** តទៅនេះហៅថា "**កិច្ចសន្យា**" នេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..... ខែ...... ឆ្នាំ.......... ដោយ និងរវាង៖

លោក/លោកស្រី ................................ កាន់អត្តសញ្ញាណសញ្ញាតិខ្មែរលេខ .............................. ចុះថ្ងៃទី ........ខែ...... ឆ្នាំ.......... មានអាសយដ្ឋានបច្ចុប្បន្ននៅ............................................តទៅហៅថា **ភាគី "ក"**។

លោក/លោកស្រី ................................ កាន់អត្តសញ្ញាណសញ្ញាតិខ្មែរលេខ .............................. ចុះថ្ងៃទី ........ខែ...... ឆ្នាំ.......... មានអាសយដ្ឋានបច្ចុប្បន្ននៅ........................................... តទៅហៅថា **ភាគី "ខ"**។

ចាប់ពីពេលនេះតទៅហៅរួមគ្នាថា "**ភាគីទាំងពីរ**" និងហៅដាច់ពីគ្នាថា "**ភាគី**"។

**ដោយហេតុថា៖**

ក. **ភាគី "ក"** ជាកម្មសិទ្ធករនៃអចលនវត្ថុមួយកន្លែង ដែលមានទីតាំងស្ថិតនៅ ....................................... តទៅនេះហៅថា "**អចលនវត្ថុ**")។

ខ. **ភាគី "ក"** យល់ព្រមជួលផ្ទៃកមួយនៃអគារខាងលើ ទៅឲ្យ**ភាគី "ខ"** ដើម្បីប្រើ ប្រាស់ និងអាស្រ័យផលដោយយកថ្លៃឈ្នួល ដើម្បីឲ្យ**ភាគី "ខ"** ធ្វើជាការិយាល័យប្រតិបត្តិ សម្រាប់ក្រុមហ៊ុន។

### ភាគីទាំងពីរ បានព្រមព្រៀងគ្នាដូចតទៅ៖

### ប្រការ ១ រយៈពេលជួល

កិច្ចសន្យានេះមានរយៈពេល ........ (......) ឆ្នាំ ដោយរាប់គិតចាប់ពីថ្ងៃទី......... ខែ........ ឆ្នាំ.............(**ថ្ងៃចាប់ផ្តើមជួល**) រហូតដល់ថ្ងៃទី........ ខែ......ឆ្នាំ.................. (**ថ្ងៃឈប់ជួល**)។

### ប្រការ ២ ថ្លៃឈ្នួល

២.១ **ភាគី "ខ"**យល់ព្រមបង់ប្រាក់ឈ្នួលប្រចាំខែ ចំនួន.............ដុល្លារអាមេរិក (......... ដុល្លារសហរដ្ឋអាមេរិក ) ឲ្យទៅ**ភាគី "ក"** ។

២.២ **ភាគី "ខ"** ត្រូវបង់ប្រាក់ឈ្នួលក្នុងអំឡុងពេលសប្តាហ៍ទីមួយ រៀងរាល់ដើមខែ នៃខែនីមួយៗ។

២.៣ ពន្ធលើថ្លៃជួល គឺជាបន្ទុករបស់**ភាគី "ខ"** ដែលត្រូវបង់។

### ប្រការ ៣ ប្រាក់កក់

៣.១ នៅថ្ងៃចុះកិច្ចសន្យានេះ **ភាគី "ខ"** ត្រូវបង់ប្រាក់កក់ថ្លៃជួល ចំនួន ............... ដុល្លារ អាមេរិក (................ ដុល្លារសហរដ្ឋអាមេរិក) មកឲ្យ **ភាគី "ក"** តទៅនេះហៅថា "**ប្រាក់កក់**" ដែលស្មើនឹងចំនួនប្រាក់ឈ្នួលចំនួន ...... (....) ខែ ដែលបានព្រមព្រៀងគ្នានៅក្នុងកិច្ចសន្យានេះ ។

៣.២ ប្រាក់កក់នេះត្រូវរក្សាទុកនៅ **ភាគី "ក"** ដើម្បីទុកជាប្រាក់ធានាក្នុងការអនុវត្តកាតព្វកិច្ចក្រោម កិច្ចសន្យានេះដោយ**ភាគី "ខ"** ហើយដែលប្រាក់កក់នេះអាចត្រូវបានកាត់យក ឬដកហូតដោយ**ភាគី "ខ"** វិញនៅថ្ងៃផុតកំណត់ ឬថ្ងៃបញ្ចប់កិច្ចសន្យានេះ ។

៣.៣ ប្រសិនបើ**ភាគី "ខ"** បញ្ចប់កិច្ចសន្យានេះ ដោយមិនគោរពទៅតាម ខ និងលក្ខខណ្ឌ ណាមួយដែលមានចែងនៅក្នុងកិច្ចសន្យានេះ ប្រាក់កក់នេះនឹងត្រូវ បានជាប្រយោជន៍ដល់**ភាគី "ក"** ។

## ប្រការ ៤ ភាគព្វកិច្ចរបស់ភាគី "ខ"

៤.១ **ភាគី "ខ"** មិនត្រូវយកទីតាំងដែលបានជួលនេះមកប្រកបអាជីវកម្មណាមួយ ដែលផ្ទុយ នឹងគោលបំណងដូចមានចែងក្នុងកិច្ចសន្យានេះ និង ដោយគ្មានច្បាប់អនុញ្ញាតឡើយ ។

៤.២ **ភាគី "ខ"** ត្រូវទទួលខុសត្រូវលើការបង់ពន្ធដារ និងពន្ធអាករផ្សេងៗ ចំពោះមុខច្បាប់ទាំងស្រុង ដោយ**ភាគី "ក"** មិនទទួលខុសត្រូវឡើយ ។

៤.៣ **ភាគី "ខ"** មិនត្រូវទុកដាក់សម្ភារៈ ឬទំនិញអ្វីដែលមានកំដៅខ្ពស់ ឬមានក្លិនអសោច ឬផ្ទុកអាវុធគ្រឿងផ្ទុះ ឬគ្រឿងញៀនគ្រប់ប្រភេទ ឬជាតិពុលគីមី ឬសម្ភារៈងាយឆេះនោះឡើយ។ ក្នុងករណីមិនគោរព ហើយបង្កឲ្យមានគ្រោះថ្នាក់ ឬការខូចខាតទ្រព្យសម្បត្តិ របស់អ្នកជិតខាងនោះ **ភាគី "ខ"** ជាអ្នកទទួលខុសត្រូវទាំងស្រុងចំពោះសំណង ការខូចខាត និងចំពោះមុខច្បាប់។

៤.៤ **ភាគី "ខ"** ត្រូវទទួលខុសត្រូវថែរក្សាទីតាំងជួលឲ្យបានល្អក្នុងរយៈពេលជួល។ រាល់ការចំណាយ ផ្សេងៗទៅលើការជួសជុលរក្សាទីតាំងជួលក្នុងរយៈពេលជួល ជាបន្ទុករបស់**ភាគី "ខ"** ។

៤.៥ **ភាគី "ខ"** មានកាតព្វកិច្ចបង់ប្រាក់ថ្លៃពន្ធផ្សេងៗ ដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់ ខ្លួនក្នុងរយៈពេលនៃការជួលនេះ។

៤.៦ នៅពេលបញ្ចប់កិច្ចសន្យានេះ **ភាគី "ខ"** មានសិទ្ធិយកទៅវិញនូវរាល់សម្ភារៈទាំងឡាយ ដែលខ្លួនបានយកមកប្រើប្រាស់ក្នុងរយៈពេលជួល បើសម្ភារៈណាមួយដែលមិនអាចយកទៅបាន ឬបណ្តាលឲ្យមានការខូចខាតដល់ផ្ទះនៅពេលដែលយកចេញនោះ **ភាគី "ខ"** ពុំមានសិទ្ធិយកចេញនោះទេ ហើយសម្ភារៈនោះនឹងក្លាយទៅជាកម្មសិទ្ធិស្របច្បាប់របស់**ភាគី "ក"** ។

## ប្រការ ៥ ភាគព្វកិច្ចរបស់ភាគី "ក"

៥.១ **ភាគី "ក"** ត្រូវធានាថាខ្លួនពិតជាកម្មសិទ្ធិករនៃអចលនវត្ថុពិតប្រាកដមែន។

៥.២ **ភាគី "ក"** មិនទទួលខុសត្រូវអ្វីឡើយនូវរាល់សកម្មភាពមិនស្របច្បាប់ណាមួយរបស់ **ភាគី "ខ"** ។

៥.៣ នៅក្នុងរយៈពេលជួល **ភាគី "ក"** មានសិទ្ធិចូលពិនិត្យផ្ទះបាន ដោយធ្វើការ ជូនដំណឹងជាមុនយ៉ាងតិច ២ (ពីរ)ថ្ងៃទៅឲ្យ**ភាគី "ខ"** បានដឹង ។

## ប្រការ ៦ ប្រការទូទៅ

៦.១ នៅក្នុងករណីប្រធានសក្តិ ដូចជា ទឹកជំនន់ រញ្ជួយដី សង្គ្រាមស៊ីវិល ខ្យល់ព្យុះ ឬមូលហេតុអ្វីផ្សេងទៀតដែលភាគីទាំងពីរមិនអាចគ្រប់គ្រងបាន និងកំហុសដែលមិនមែនកើតឡើងដោយការធ្វេស

ប្រហែស ឬកំហុសផ្សេងៗទៀតដែលមិនអាចឲ្យ **ភាគី "ខ"** ប្រើប្រាស់ទីតាំងជួលបាននោះ ក្នុងករណីនេះគ្មានភាគីណាមួយត្រូវទទួលខុសត្រូវលើការខកខាន ឬការពន្យាពេលក្នុងការអនុវត្តកិច្ចសន្យានេះឡើយ ហើយភាគីនីមួយៗមានសិទ្ធិ បញ្ចប់កិច្ចសន្យានេះ ដោយធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅឲ្យភាគីម្ខាងទៀត យ៉ាងតិចបំផុត ៣០ (សាមសិប)ថ្ងៃ មុនធ្វើការបញ្ចប់កិច្ចសន្យា។

៦.២ **ភាគី "ក"** អាចធ្វើការបញ្ចប់កិច្ចសន្យានេះបាន ប្រសិនបើ**ភាគី "ខ"** មិនបានបង់ប្រាក់ឈ្នួលក្នុងរយៈពេល ១(មួយ)ខែ រាប់គិតចាប់ពីថ្ងៃកំណត់ត្រូវបង់ប្រាក់ឈ្នួល។

៦.៣ នៅក្នុងករណីដែលភាគីណាមួយពុំអាចអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនបណ្តាលមកពីមរណៈភាព ពិការភាព ឬអវត្តមានពីក្នុងប្រទេស បទបញ្ញត្តិនៃកិច្ចសន្យានេះ ត្រូវភ្ជាប់កាតព្វកិច្ចផងដែរទៅលើទាយាទ អ្នកស្នង និងអ្នកទទួលសិទ្ធិរបស់ភាគីទាំងពីរដែលបានតែងតាំង ទទួលសិទ្ធិ និងមានការអនុញ្ញាត។ អ្នកទទួលសិទ្ធិពីភាគីណាមួយនោះ ត្រូវធ្វើការជូនដំណឹងភាគីម្ខាងទៀត ឲ្យបានដឹងនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ រាប់ គិតចាប់ពីថ្ងៃដែលទទួលបានសិទ្ធិនោះ ដោយភ្ជាប់មកជាមួយនូវរាល់ឯកសារផ្លូវច្បាប់ផ្សេងៗដែលបញ្ជាក់ពីលទ្ធភាពរបស់ខ្លួនក្នុងការទទួលសិទ្ធិ។

៦.៤ កិច្ចសន្យានេះត្រូវស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ហើយមានសុពលភាពអនុវត្តតាមផ្លូវច្បាប់ ចាប់ពីថ្ងៃចុះហត្ថលេខា ឬផ្តិតស្នាមមេដៃនេះតទៅ។

៦.៥ កិច្ចព្រមព្រៀងនេះ ត្រូវបានធ្វើឡើងជាភាសាខ្មែរ ចំនួន ០២(ពីរ)ច្បាប់ដើម ដែលច្បាប់នីមួយៗមានតម្លៃស្មើៗគ្នា។

**ដើម្បីជាសក្ខីភាពនៃសេចក្តីខាងលើ ភាគី "ក"** និង**ភាគី "ខ"** តាមរយៈកិច្ចសន្យានេះ ចុះហត្ថលេខា ខាងក្រោមទទួលស្គាល់ និងប្រតិបត្តិតាម ខ និងលក្ខខណ្ឌទាំងឡាយដែលមានចែងនៅក្នុងកិច្ចសន្យានេះ នូវកាលបរិច្ឆេទដូចមានចែងខាងលើ។

| | |
|---|---|
| **ភាគី "ក"** | **ភាគី "ខ"** |
| (ហត្ថលេខា ឬស្នាមមេដៃ) | (ហត្ថលេខា ឬស្នាមមេដៃ) |
| ________________________ | ________________________ |
| ........................... | ........................... |

គំរូកិច្ចសន្យា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
..........

# <u>កិច្ចសន្យាលក់-ទិញអចលនវត្ថុ (ដី)</u>

កិច្ចសន្យាលក់-ទិញអចលនវត្ថុនេះ «**កិច្ចសន្យា**» ធ្វើឡើងនៅថ្ងៃទី.... ខែ......ឆ្នាំ..........រវាង៖

**ភាគី "ក" ៖**

. ឈ្មោះ៖ លោក/លោកស្រី............
. ថ្ងៃ ខែ ឆ្នាំកំណើត៖ ..................................
. សញ្ជាតិ៖ ខ្មែរ
. អត្តសញ្ញាណប័ណ្ណ៖ លេខ.................... ចុះថ្ងៃទី......ខែ......ឆ្នាំ............
. ទីលំនៅបច្ចុប្បន្ន៖ ............................................
. ចាប់ពីពេលនេះតទៅហៅកាត់ថា "**អ្នកលក់**"។ **និង**

**ភាគី "ខ" ៖**

ឈ្មោះ៖ លោក/លោកស្រី............
. ថ្ងៃ ខែ ឆ្នាំកំណើត៖ ..................................
. សញ្ជាតិ៖ ខ្មែរ
. អត្តសញ្ញាណប័ណ្ណ៖ លេខ.................... ចុះថ្ងៃទី......ខែ......ឆ្នាំ............
. ទីលំនៅបច្ចុប្បន្ន៖ ............................................
. ចាប់ពីពេលនេះតទៅហៅកាត់ថា "**អ្នកទិញ**"។

ភាគីទាំងពីរត្រូវបានហៅដាច់ដោយឡែកពីគ្នាថា "**ភាគីនីមួយៗ**" និងហៅរួមគ្នាថា "**គូភាគី**"។

**ដោយហេតុថា៖**

- **អ្នកលក់** គឺជាម្ចាស់អចលនវត្ថុ (ដី) ដែលមានទំហំសរុប ............... ម៉ែត្រក្រឡា ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ..................... ចុះថ្ងៃទី...... ខែ......... ឆ្នាំ.......... ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី............... មានទីតាំងស្ថិតនៅ.......................................................។
- **អ្នកលក់** មានបំណងលក់ ហើយ**អ្នកទិញ** មានបំណងទិញអចលនវត្ថុ (ដី) ខាងលើមួយចំណែកដែលមានទំហំ..............................ម៉ែត្រក្រឡា ដោយកាត់ចេញពីដីសរុបខាងលើ ហើយភាគីទាំងពីរបានពិភាក្សាគ្នាអំពីខ និងលក្ខខណ្ឌនៃកិច្ចសន្យាទិញលក់អចលនវត្ថុនេះ។

**ក្រោយពីបានពិភាក្សាគ្នារួចមក គូភាគីបានព្រមព្រៀងគ្នាដូចខាងក្រោម ៖**

## ប្រការ ១៖ កម្មវត្ថុនៃកិច្ចសន្យា

១.១. **អ្នកទិញ** យល់ព្រមទិញ ហើយ**អ្នកលក់** យល់ព្រមលក់ អចលនវត្ថុមួយកន្លែងមានទំហំ................... ម៉ែត្រក្រឡា ជាចំណែកនៃអចលនវត្ថុ (ដី) នៅក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ

.................... ចុះថ្ងៃទី...... ខែ...... ឆ្នាំ........... ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី...............មានទីតាំងស្ថិតនៅ....................................................។

១.២. អចលនវត្ថុនេះរួមបញ្ចូលនូវដី ដើមរុក្ខជាតិ សំណង់ និងចលនទ្រព្យ ដែលភ្ជាប់ទៅនឹងដីនោះ (ករណីបើមាន)។

## ប្រការ ២៖ តំលៃលក់-ទិញ

២.១. អចលនវត្ថុខាងលើមានតម្លៃ ................................ ក្នុងមួយម៉ែត្រក្រឡា ដែលមានតម្លៃសរុបចំនួន ........................................។

២.២. តម្លៃខាងលើនេះរួមបញ្ចូលនូវពន្ធទាំងឡាយ ថ្លៃឈ្នួល និងការចំណាយដែលពាក់ព័ន្ធទៅនឹងការចុះបញ្ជីផ្ទេរកម្មសិទ្ធិដី ពី**អ្នកលក់** ទៅ **អ្នកទិញ** ទៅតាមនីតិវិធីច្បាប់។

## ប្រការ ៣៖ ការបង់ប្រាក់កក់ និងប្រាក់ថ្លៃលក់ទិញ

៣.១. **អ្នកទិញ** ត្រូវបង់ប្រាក់កក់ និងប្រាក់ថ្លៃលក់ទិញអចលនវត្ថុខាងលើមកឲ្យ**អ្នកលក់** ទៅតាមលក្ខខណ្ឌ និងកាលបរិច្ឆេទដូចខាងក្រោម៖

- **ដំណាក់កាលទី ១៖** បង់ប្រាក់កក់ចំនួន.................. ស្មើនឹង ២០% នៃតម្លៃលក់ទិញសរុប នៅថ្ងៃចុះកិច្ចសន្យានេះ។
- **ដំណាក់កាលទី ២៖** បង់ប្រាក់ថ្លៃទិញលក់ចំនួន..................... ស្មើនឹង ១០% នៃតម្លៃលក់ទិញសរុប នៅថ្ងៃទី...... ខែ...... ឆ្នាំ............។
- **ដំណាក់កាលទី ៣៖** បង់ប្រាក់ថ្លៃលក់ទិញចំនួន..................ស្មើនឹង ២០% នៃតម្លៃលក់ទិញសរុប នៅពេលដែល អ្នកលក់ បានផ្ទេរកម្មសិទ្ធិ (ប្លង់រឹង) នៃអចលនវត្ថុដែលលក់នេះមកជាកម្មសិទ្ធិរបស់អ្នកទិញរួចរាល់ ។
- **ដំណាក់កាលទី ៤៖** បង់ប្រាក់ថ្លៃលក់ទិញបង្គ្រប់ចំនួន ....................... យ៉ាងយូររយៈពេល ១២ ខែបន្ទាប់ពីទទួលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ។
  ការប្រគល់ប្រាក់ថ្លៃលក់ទិញបង្គ្រប់ត្រូវធ្វើឡើងជាមួយគ្នានឹងការប្រគល់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលលក់ទិញនេះជាឯកសារដើមពីភាគី **អ្នកលក់** ទៅភាគី**អ្នកទិញ** ។

៣.២. រាល់ការបង់ប្រាក់កក់ និងប្រាក់ថ្លៃលក់ទិញទាំងអស់ដោយ **អ្នកទិញ** មកឲ្យ**អ្នកលក់** ត្រូវធ្វើឡើងតាមរយៈការផ្តល់ជាសាច់ប្រាក់ ឬមូលប្បទានបត្រ ឬការផ្ទេរប្រាក់ចូលគណនីធនាគាររបស់ **អ្នកលក់**។

## ប្រការ ៤៖ សិទ្ធិ និងភាតព្វកិច្ចរបស់អ្នកលក់

ក្រោមកិច្ចសន្យានេះ **អ្នកលក់** មានសិទ្ធិ និងកាតព្វកិច្ចដូចខាងក្រោម៖

- **អ្នកលក់** គឺជាម្ចាស់កម្មសិទ្ធិនៃអចលនវត្ថុពីដែលលក់នេះ ប្រាកដមែន។
- **អ្នកលក់** មានសមត្ថភាព និងសិទ្ធិតាមផ្លូវច្បាប់ពេញលេញក្នុងការចុះកិច្ចសន្យានេះ ។
- ទទួលប្រាក់ថ្លៃលក់ទិញគ្រប់ដំណាក់កាលពីអ្នកទិញ ទៅតាមកាលបរិច្ឆេទកំណត់ក្នុងកិច្ចសន្យានេះ ដោយចេញលិខិតទទួលប្រាក់ត្រឹមត្រូវ និងគ្រប់ដំណាក់កាល។
- រត់ការចុះបញ្ជីផ្ទេរកម្មសិទ្ធិអចលនវត្ថុដែលលក់នេះ ដោយការចុះបញ្ជីបំបែកក្បាលដីចេញពីដីដែលមានប្លង់រួម ទៅឲ្យ **អ្នកទិញ** ដោយមានការសហការពេញលេញពី **អ្នកទិញ** និងដាក់ឈ្មោះ **អ្នកទិញ** ជាម្ចាស់កម្មសិទ្ធិនៅក្នុងប័ណ្ណទៅតាមលក្ខខណ្ឌនៃកិច្ចសន្យានេះ។

- ចេញចំណាយទាំងស្រុងលើការចុះបញ្ជីផ្ទេរកម្មសិទ្ធិ ពន្ធលើការផ្ទេរកម្មសិទ្ធិដី និងពន្ធផ្សេងទៀត ដែលមានគិតត្រឹមកាលបរិច្ឆេទនៃការផ្ទេរកម្មសិទ្ធិដាក់ឈ្មោះ អ្នកទិញ ជាម្ចាស់រួចរាល់។
- ត្រូវជូនដំណឹងទៅ **អ្នកទិញ** ករណីដែលអ្នកលក់ បានផ្ទេរកម្មសិទ្ធិនៃដីនេះរួចរាល់ ហើយត្រូវថតចម្លងឯកសារកម្មសិទ្ធិដីដែលមានឈ្មោះ **អ្នកទិញ** នៅក្នុងប័ណ្ណ ដើម្បីឲ្យអ្នកទិញ យកទៅផ្ទៀងផ្ទាត់ជាមួយស្ថាប័នមានសមត្ថកិច្ចអំពីភាពត្រឹមត្រូវនៃការផ្ទេរកម្មសិទ្ធិនេះ។
- ប្រគល់អចលនវត្ថុនេះទៅអ្នកទិញ នៅពេលដែលអ្នកទិញបានប្រគល់ប្រាក់ថ្លៃលក់ទិញគ្រប់ចំនួនឲ្យអ្នកលក់។

## ប្រការ ៥៖ សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកទិញ

ក្រោមកិច្ចសន្យានេះ **អ្នកទិញ** មានសិទ្ធិ និងកាតព្វកិច្ចដូចខាងក្រោម៖

- មានសិទ្ធិ និងសមត្ថភាពពេញលេញក្នុងការចុះកិច្ចសន្យានេះ។
- បង់ប្រាក់ថ្លៃលក់ទិញគ្រប់ចំនួន និងស្របតាមកាលបរិច្ឆេទដែលបានកំណត់ ឲ្យមក **អ្នកលក់**។
- សហការ ផ្តិតមេដៃ និងចុះហត្ថលេខាលើឯកសារចាំបាច់ទាំងឡាយ ក្នុងដំណើរការចុះបញ្ជីផ្ទេរកម្មសិទ្ធិដី ពីឈ្មោះ**អ្នកលក់** មកឈ្មោះរបស់អ្នកទិញ ទៅតាមលក្ខខណ្ឌតម្រូវដោយអាជ្ញាធរមានសមត្ថកិច្ច និងស្របតាមនីតិវិធីច្បាប់កម្ពុជា។

## ប្រការ ៦៖ ការមិនអនុវត្តកាតព្វកិច្ច

៦.១. ប្រសិនបើ **អ្នកទិញ** បញ្ចប់ការទិញលក់នេះដោយឯកតោភាគី នោះការទិញលក់នឹងត្រូវបញ្ចប់ ហើយប្រាក់កក់ និងប្រាក់ថ្លៃលក់ទិញ ដែលអ្នកទិញបានបង់ទៅ**អ្នកលក់** រួចហើយនឹងត្រូវជាប្រយោជន៍របស់**អ្នកលក់** ។ ក្នុងករណីដែលអ្នកទិញ មិនបានបង់ប្រាក់ថ្លៃទិញលក់នេះតាមការកំណត់ទេនោះ ឬបំពានលក្ខខណ្ឌផ្សេងទៀតនៃកិច្ចសន្យានេះ អ្នកលក់ មានសិទ្ធិបញ្ចប់/រំលាយកិច្ចសន្យាលក់ទិញនេះ ប្រសិនបើអ្នកទិញ មិនបានកែប្រែការបំពានកាតព្វកិច្ចរបស់ខ្លួន រយៈពេល ៦០ (ហុកសិប) ថ្ងៃ បន្ទាប់ទទួលបានការជូនដំណឹងពី **អ្នកលក់** ហើយប្រាក់កក់ និងប្រាក់ថ្លៃលក់ទិញទាំងអស់ដែលបង់រួចហើយដោយ**អ្នកទិញ** ត្រូវក្លាយជាប្រយោជន៍ ឬកម្មសិទ្ធិរបស់**អ្នកលក់** ជាស្វ័យប្រវត្តិ។ ប្រសិនបើអ្នកលក់បានចុះបញ្ជីផ្ទេរកម្មសិទ្ធិដីទៅឲ្យអ្នកទិញរួចហើយតាមកិច្ចសន្យានេះ នោះភាគី **អ្នកទិញ** មានកាតព្វកិច្ចចុះបញ្ជីផ្ទេរកម្មសិទ្ធិត្រឡប់មកឲ្យភាគី **អ្នកលក់** វិញដោយគ្មានលក្ខខណ្ឌ និងឆាប់រហ័ស។

៦.២. ប្រសិនបើ **អ្នកលក់** កែប្រែដោយមិនលក់អចលនវត្ថុនេះទៅឲ្យ **អ្នកទិញ** ឬបានលក់អចលនវត្ថុនេះទៅតតីយជន ឬមិនអាចចុះបញ្ជីផ្ទេរកម្មសិទ្ធិអចលនវត្ថុនេះឲ្យ**អ្នកទិញ** ក្នុងពេលកំណត់ និងមិនសមហេតុផលនោះ**អ្នកទិញ** មានជម្រើសបន្តការទិញ ឬ បញ្ចប់ការទិញលក់នេះ ដោយតម្រូវឲ្យ **អ្នកលក់** ប្រគល់ប្រាក់កក់ និងប្រាក់ថ្លៃលក់ទិញ ដែលទទួលពី**អ្នកទិញ** រួចហើយ មកឲ្យអ្នកទិញវិញ ស្មើនឹងចំនួន ២ ដង។

## ប្រការ ៧៖ ការអនុវត្តចំពោះសន្តតិជន

សិទ្ធិទាំងឡាយរបស់គូភាគីនៅក្នុងកិច្ចសន្យានេះ ត្រូវមានអានុភាព ជាប្រយោជន៍ដល់សន្តតិជនរបស់គូភាគីទៅតាមនីតិវិធីច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៨៖ ច្បាប់គ្រប់គ្រង និងការដោះស្រាយវិវាទ

៨.១. កិច្ចព្រមព្រៀងនេះត្រូវបានបកស្រាយ និងគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

៨.២. ករណីដែលមានវិវាទកើតឡើងទាក់ទងទៅនឹងកិច្ចសន្យានេះ គូភាគីត្រូវជួបដោះស្រាយជាមួយគ្នាដោយសន្តិវិធី និងមិត្តភាព។ ក្នុងករណីដែលភាគីទាំងពីរមិនអាចដោះស្រាយវិវាទនេះបានដោយសន្តិវិធីទេនោះ គូភាគីព្រមព្រៀងបញ្ជូនវិវាទនេះទៅដោះស្រាយនៅតុលាការដែលមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៩៖ កិច្ចព្រមព្រៀងទាំងមូល

កិច្ចព្រមព្រៀងនេះបង្កើតជាកិច្ចព្រមព្រៀងទាំងមូលរបស់គូភាគី។ ការព្រមព្រៀង ការសន្យា និងកិច្ចព្រមព្រៀងណាដែលមានពីមុន ទោះជាដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរក្តី ដែលមានវិវាទជាមួយកិច្ចព្រមព្រៀងនេះ ត្រូវចាត់ទុកជាមោឃៈ។ ពុំមានការកែប្រែណាលើកិច្ចព្រមព្រៀងនេះត្រូវមានប្រសិទ្ធភាពឡើយ ដរាបណាមិនត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានផ្តិតមេដៃដោយគូភាគីទេនោះ។

## ប្រការ ១០៖ ភាពដាច់ដោយឡែកពីគ្នានៃប្រការនីមួយៗ

ប្រសិនបើមានបញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះត្រូវចាត់ទុកថាមិនមានសុពលភាព ឬមិនអាចអនុវត្តបាន កិច្ចព្រមព្រៀងនេះត្រូវបកស្រាយថាមិនមាននូវបញ្ញត្តិទាំងនោះឡើយ ហើយសិទ្ធិ និងកាតព្វកិច្ចរបស់គូភាគីនៅក្នុងកិច្ចព្រមព្រៀងនេះត្រូវបកស្រាយ និងអនុវត្តដូចជាមិនមាននូវបញ្ញត្តិទាំងនោះដែរ។

## ប្រការ ១១៖ ការជូនដំណឹង

គូភាគីទទួលស្គាល់នូវមធ្យោបាយសម្រាប់ទំនាក់ទំនងរវាងគ្នានឹងគ្នាដូចខាងក្រោម៖

**ទៅកាន់អ្នកលក់ ៖**

ជូនចំពោះ ៖ លោក/លោកស្រី...................................

អាសយដ្ឋាន ៖ .........................................................

ទូរស័ព្ទ ៖ .............................

**ទៅកាន់អ្នកទិញ ៖**

ជូនចំពោះ ៖ លោក/លោកស្រី...................................

អាសយដ្ឋាន ៖ .........................................................

ទូរស័ព្ទ ៖ .............................

## ប្រការ ១២៖ ភាសា

កិច្ចសន្យានេះត្រូវបានធ្វើឡើងជាភាសាខ្មែរ ចំនួន៣ (បី) ច្បាប់ មានខ្លឹមសារដូចគ្នា ដោយប្រគល់ជូនគូភាគីម្នាក់មួយច្បាប់ និងមួយច្បាប់ទៀតតម្កល់នៅមន្ទីរសារការី..........................។

**ដើម្បីជាសក្ខីភាពនៃការលក់ទិញនេះ អ្នកលក់** និងអ្នកទិញ តាមរយៈការចុះហត្ថលេខានិងការផ្តិតស្នាមមេដៃខាងក្រោម នៅកាលបរិច្ឆេទដូចបានសរសេរនៅខាងលើបង្អស់នៃកិច្ចព្រមព្រៀងនេះ ទទួលស្គាល់ និងយល់ព្រមលើលក្ខខណ្ឌផ្សេងៗនៃកិច្ចព្រមព្រៀងនេះ។

**អ្នកលក់** **អ្នកទិញ**

លោក/លោកស្រី.................. លោក/លោកស្រី................

បានឃើញនិងបញ្ជាក់ថា
ភាគីទាំងអស់ពិតជាបានផ្តិតមេដៃចំពោះមុខសារការីពិតប្រាកដមែន។
រាជធានីភ្នំពេញ ថ្ងៃទី...... ខែ........ឆ្នាំ..............

គំរូពាក្យសុំ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុង-ស្រុក-ខណ្ឌ....................

ឃុំ-សង្កាត់:..............................

# លិខិតបញ្ជាក់កម្មសិទ្ធិដីធ្លី

យើងមេឃុំ-ចៅសង្កាត់.......................ក្រុង-ស្រុក-ខណ្ឌ......................ខេត្ត.............................

**សូមបញ្ជាក់ថា:**

អចលនទ្រព្យដែលមាន ................................................................ លេខ.........................ចុះថ្ងៃទី................ ខែ................ ឆ្នាំ................ ចេញដោយ ............................................................... និង ............................................................. លេខ....................... ចុះថ្ងៃទី........... ខែ............... ឆ្នាំ................ ចេញដោយ ............................................................................ ដូចបានភ្ជាប់មកជាមួយ ដែលមានទីតាំងស្ថិតនៅភូមិ.................... ឃុំ-សង្កាត់.................... ក្រុង-ស្រុក-ខណ្ឌ.................... ខេត្ត...................... មានទំហំ...................... ដែលមានព្រំប្រទល់:

-ខាងជើង: ទល់នឹង.................................................... - ខាងត្បូង: ទល់នឹង....................................................

-ខាងកើត: ទល់នឹង.................................................... - ខាងលិច: ទល់នឹង....................................................

ពិតជាកម្មសិទ្ធិស្របច្បាប់របស់ឈ្មោះ....................... ភេទ.......... អាយុ.......... ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ........................................ ចុះថ្ងៃទី...... ខែ......... ឆ្នាំ............ និង ឈ្មោះ.................................... ភេទ.......... អាយុ............. ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ............................................ចុះថ្ងៃទី....... ខែ......... ឆ្នាំ......... ត្រូវជា.......................... អាសយដ្ឋានបច្ចុប្បន្ន: ផ្ទះលេខ .........ក្រុមទី............. ផ្លូវលេខ............ ភូមិ..................... ឃុំ-សង្កាត់:........................ ក្រុង-ស្រុក-ខណ្ឌ....................រាជធានី-ខេត្ត.........................។ តាមរយៈ ទិញ/អំណោយ ពីឈ្មោះ:.................................. ដែលឈ្មោះ:.............................................. នេះបានកាន់កាប់ តាំងពីឆ្នាំ ..................... តាមរយៈ .......................... ពិតប្រាកដមែន។

**ចំពោះអចលនទ្រព្យនេះ:**

-ពុំទាន់បានទទួលវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬលិខិតស្នាមផ្សេងៗដែលបញ្ជាក់ពីកម្មសិទ្ធិអចលនទ្រព្យ។

-ពុំមានដាក់បញ្ចាំ ឬធ្វើអំណោយទៅឲ្យជនណាមួយឡើយ។

-ពុំមានពាក់ព័ន្ធទំនាស់ ឬដីកាហាមឃាត់របស់តុលាការឡើយ។

-ពុំមានពាក់ព័ន្ធដីសាធារណៈដែលរដ្ឋហាមឃាត់ឡើយ។

យើងចេញលិខិតនេះឲ្យម្ចាស់កម្មសិទ្ធិដើម្បីយកទៅប្រើប្រាស់ជាផ្លូវការតាមច្បាប់។

លេខ:..............................

បានឃើញ និងបញ្ជាក់ថា

ហត្ថលេខាខាងស្តាំនេះពិតជាហត្ថលេខា របស់មេភូមិ.................ពិតប្រាកដមែន។

ថ្ងៃ......................ខែ...........ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

...........,ថ្ងៃទី...........ខែ........ឆ្នាំ២០២១

**មេឃុំ**.....................

ហត្ថលេខា និងត្រា

ថ្ងៃ......................ខែ...........ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

...........,ថ្ងៃទី...........ខែ........ឆ្នាំ២០២១

**មេភូមិ**............

ហត្ថលេខា

ឈ្មោះ:..............................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ

លេខ : 12010604-0005

| | | | |
|---|---|---|---|
| រាជធានី/ខេត្ត : ភ្នំពេញ | | សន្លឹកផែនទីលេខ : | 5932-II 94 b 4 |
| ក្រុង/ស្រុក/ខណ្ឌ : ចំការមន | | លេខក្បាលដី : | 5 |
| ឃុំ សង្កាត់ : ទួលស្វាយព្រៃទី ១ | | ទំហំ : | 107 ម៉ែ២ |
| ភូមិ : ៤ | | ប្រភេទដី : | |
| | | រូបភាពប្រើប្រាស់ដី : | លំនៅឋាន |
| | | លក្ខណៈនៃការប្រើប្រាស់ដី : | ឯកជន |




មាត្រដ្ឋាន 1/600

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥...

ធ្វើនៅភ្នំពេញ.ថ្ងៃទី ខែ ឆ្នាំ ២០...

តប.ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី

គំរូសន្លឹកប័ណ្ណថ្មី

No. 04699002

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ)

អាសយដ្ឋាន : ទីស្នាក់ការលេខ ៤៥ ផ្លូវលេខ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ : ០២៣ ៦២៤ ៨០៨០ / ០២៣ ៧២៤ ០៤៦

| | | | |
|---|---|---|---|
| ឈ្មោះ | : | | |
| ផ្ទះលេខ | : N# 54 E0 K | | |
| ផ្លូវលេខ | : 3 | លេខវិក្កយបត្រ | : PPWSA2510196798 |
| លេខអតិថិជន | : WP | រយៈពេល | : 12/07/2025-10/09/2025 |
| លេខទីតាំង | : 01 07 21 6815 1 | ថ្ងៃធ្វើវិក្កយបត្រ | : 10/09/2025 09:37:58 |
| លេខនាឡិកា | : KE23 15 | ចំណាត់ថ្នាក់ | : 11 - 04 |

| អំណានចាស់ | 145 | អំណានថ្មី | 197 | បរិមាណទឹក | 52 |
|---|---|---|---|---|---|

| បរិយាយ | បរិមាណ | តម្លៃឯកតា (៛) | ទឹកប្រាក់ (៛) |
|---|---|---|---|
| ថ្លៃទឹកតាមនាឡិកាស្ទង់កំរិត១ | 30.0M3 | 950.00 | 28,500.00 |
| ថ្លៃទឹកតាមនាឡិកាស្ទង់កំរិត២ | 22.0M3 | 1,100.00 | 24,200.00 |
| វិភាគទានលូទឹកស្អុយ | 10% | 527.00 | 5,270.00 |
| ថ្លៃថែទាំនាឡិកាស្ទង់ | 2 M | 750.00 | 1,500.00 |
| ទឹកប្រាក់ឬកបង្គត់ | 1 | 30.00 | 30.00 |

ប្រាក់កក់របស់លោក-អ្នក : 760,000 ៛

| | | |
|---|---|---|
| - ០២៣ ៦២៤ ០៨០៨ (២៤ម៉ោង) ករណីធ្លាយទឹកតាមផ្លូវសាធារណៈ ឬ ដឹកការបំពុះបណ្តាញទឹក។ - ០២៣ ៦៣២ ០១៦៨ (ពីម៉ោង ០៧:០០ ដល់ ១៦:៣០) បម្រើសេវាអតិថិជន។ | ទឹកប្រាក់ត្រូវបង់លើកនេះ | 59,500 ៛ |
| | ជំពាក់ (ខែមុន) | 0 ៛ |
| | ទឹកប្រាក់ត្រូវបង់ | 59,500 ៛ |
| | ការបង់ប្រាក់ | 12.09.25 (14.87 USD) |

សូមបង់ប្រាក់មុនថ្ងៃ : 25/09/2025 ទូរស័ព្ទទំនាក់ទំនង : 0967777827

---

| | | | |
|---|---|---|---|
| ឈ្មោះ | : | | រ.ទ.ស.ភ |
| លេខទីតាំង | : 01 07 21 6 15 1 | ថ្ងៃធ្វើវិក្កយបត្រ : 10/09/25 | 52M3 |
| លេខអតិថិជន | : W813 2 | PPWS | |

| | |
|---|---|
| ទឹកប្រាក់ត្រូវបង់លើកនេះ | 59,500 ៛ |
| ទឹកប្រាក់ត្រូវបង់សរុប | 59,500 ៛ |

- សូមមេត្តាបង់ប្រាក់ថ្លៃទឹកនៅបញ្ជរបស់ រ.ទ.ស.ភ ឬតាមរយៈសេវាបង់ថៃដៃគូសហការ។ ករណីបង់ក្រៅពីនេះ រ.ទ.ស.ភ មិនទទួលខុសត្រូវឡើយ ។
- ករណីអតិថិជនពុំបានបង់ប្រាក់ តាមពេលវេលាកំណត់ រ.ទ.ស.ភ នឹងត្រូវកាត់ផ្តាច់បណ្តាញទឹក។ ដើម្បីតភ្ជាប់បណ្តាញវិញ អតិថិជនត្រូវសងបំណុលរួមទាំងប្រាក់ពិន័យ ១% ក្នុង១ថ្ងៃ និងថ្លៃសេវាតភ្ជាប់បណ្តាញជាមុនសិន ។

ចម្លងត្រឹមត្រូវ

[redacted]

INV/2019/001512

# អគ្គិសនីកម្ពុជា
ELECTRICITÉ DU CAMBODGE

**សាខាអូរបែកក្អម** ភូមិអូរបែកក្អម សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ Hotline Tel: 068, 061, 333266

អាសយដ្ឋានទទួលវិក្កយបត្រ

**លោក គន់ជួន វិចិត្រ**
ផ្ទះលេខ 57A ផ្លូវលេខ 1966 ភូមិអូរបែកក្អម សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ

អគ្គិសនីកម្ពុជា - EDC

| | |
|---|---|
| ថ្ងៃចេញវិក្កយបត្រ | 16/07/2019 |
| លេខសំគាល់អតិថិជន ID | 11529010 |
| ទីតាំងប្រើប្រាស់ចរន្ត LOCATION | P1919-2 001A RD / 1Ph x 63A |
| ប្រភេទអតិថិជន | លំនៅដ្ឋាន - R00 |

**ប្រវត្តិប្រើប្រាស់ ១២ខែចុងក្រោយ**

| | | | |
|---|---|---|---|
| 16/07/18 | 513kWh | 15/08/18 | 394kWh |
| 16/09/18 | 388kWh | 15/10/18 | 533kWh |
| 16/11/18 | 356kWh | 15/12/18 | 476kWh |
| 16/01/19 | 450kWh | 16/02/19 | 420kWh |
| 15/03/19 | 380kWh | 16/04/19 | 326kWh |
| 15/05/19 | 353kWh | 16/06/19 | 477kWh |

ប្រើប្រាស់ជាមធ្យមខែនេះ គិតជាគីឡូវ៉ាត់ក្នុងមួយថ្ងៃ 16 kWh
ប្រើប្រាស់ជាមធ្យមខែនេះ ឆ្នាំមុន គិតជាគីឡូវ៉ាត់ក្នុងមួយថ្ងៃ 19 kWh




- ក្នុងករណីអតិថិជនមិនបានបង់ប្រាក់ តាមការកំណត់នេះ អគ្គិសនីនឹងផ្អាកការផ្គត់ផ្គង់ជាបណ្ដោះអាសន្ន ។
- ការភ្ជាប់ចរន្តអគ្គិសនីឡើងវិញ លុះត្រាអតិថិជនបានបង់បំណុលសរុបក្នុងវិក្កយបត្រនេះ និងថ្លៃភ្ជាប់ចរន្តឡើងវិញរួចរាល់ហើយ ។
- អតិថិជនអាចបង់ប្រាក់ដោយផ្ទាល់ នៅតាមបញ្ជរបេឡាអគ្គិសនីកម្ពុជា ឬតាមរយៈភ្នាក់ងារទទួលបង់ប្រាក់ ( ម៉ាស៊ីន ATM, Mobile Banking, Mobile App... ) ។

ប្រសិនបើអ្នកប្រើប្រាស់មានចម្ងល់ ឬបណ្ដឹងទាក់ទងនឹងវិក្កយបត្រនេះ សូមទំនាក់ទំនងដោយផ្ទាល់ជាមួយភ្នាក់ងារទទួលខុសត្រូវរបស់សាខា ។ អគ្គិសនីកម្ពុជារក្សាសិទ្ធិមិនដោះស្រាយជូនតាមរយៈ ការបង្ហោះបង្ហាញលើប្រព័ន្ធសារព័ត៌មានសង្គម ជាលក្ខណៈបុគ្គលនោះទេ ។ អ្នកចុះផ្សាយមិនមានការទទួលខុសត្រូវ ដែលប៉ះពាល់ដល់កិត្តិយសរបស់អគ្គិសនីកម្ពុជា អាចប្រឈមមុខជាមួយច្បាប់ជាធរមាន ។

**ស្ថានភាពបំណុលចាស់ (1)**
បំណុលសរុបគិតត្រឹមថ្ងៃទី 16/07/2019 11:41 ល្ងាច — 0 ៛

**ចំនួន និងថ្លៃនៃការប្រើប្រាស់អគ្គិសនីថ្មី ចាប់ពីថ្ងៃ 12/06/2019 ដល់ 11/07/2019 ( 29 ថ្ងៃ ) (2)**

| អត្តលេខនាឡិកាស្ទង់ | អំណានចាស់ | អំណានថ្មី | មេគុណ | ថាមពលប្រើប្រាស់ | តម្លៃ | តម្លៃថាមពលសរុប |
|---|---|---|---|---|---|---|
| 105100333 | 21047 | 21499 | 1 | 452 | 740 ៛ | 334,480 ៛ |
| | | | | សរុប | | **334,480 ៛** |

# គំរូវិក្កយបត្រអគ្គិសនីថ្មី

វិក្កយបត្រ

| | |
|---|---|
| បំណុលសរុប | 334,480 ៛ |
| ទឹកប្រាក់ត្រូវបង់ (1)+(2) | **334,480 ៛** |
| ថ្ងៃផុតកំណត់បង់ប្រាក់ | 02/08/2019 |
| ថ្ងៃបង់ប្រាក់ | |
| ចំនួនទឹកប្រាក់ | |

---

លេខសំគាល់អតិថិជន ID 11529010

អតិថិជន លោក គន់ជួន វិចិត្រ

| | |
|---|---|
| ទឹកប្រាក់ត្រូវបង់ | 334,480 ៛ |
| ថ្ងៃផុតកំណត់បង់ប្រាក់ | 02/08/2019 |
| ថ្ងៃបង់ប្រាក់ | |
| ចំនួនទឹកប្រាក់បានបង់ | |

VERIGUARD ANALYTIC

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតបញ្ជាក់ការត្រួតពិនិត្យសាវតាររូបវន្តបុគ្គល

បានត្រួតពិនិត្យនៅថ្ងៃទី............ ម៉ោង

| ល.រ | ឈ្មោះ | ថ្ងៃ ខែ ឆ្នាំកំណើត | ជាប់បញ្ជីប្រុងប្រយ័ត្ន | មិនជាប់បញ្ជីប្រុងប្រយ័ត្ន |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |

*លិខិតនេះមានសុពលភាពរយៈពេល ៣ខែ*

*2025050001*

ក្រសួងពាណិជ្ជកម្ម

DOW JONES RISK AND COMPLIANCE

POWERED BY DOW JONES RISKCENTER
© 2025 Dow Jones & Company, Inc. All Right Reserved.
Person/Entity search powered by Linguistic Search Solutions